ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ

## អង្គភាពសម្របសម្រួលយុទ្ធសាស្ត្រជាតិគាំពារសង្គម

# ការគាំពារសង្គម ដើម្បីកំណើនសេដ្ឋកិច្ច ប្រកបដោយសមធម៌ ក្នុងបរិបទកម្ពុជា

ភ្នំពេញ

ខែមិថុនា ឆ្នាំ២០១៣

ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
អង្គភាពសម្របសម្រួលយុទ្ធសាស្ត្រជាតិគាំពារសង្គម

# ការគាំពារសង្គម ដើម្បីកំណើនសេដ្ឋកិច្ច ប្រកបដោយសមធម៌ក្នុងបរិបទកម្ពុជា

រៀបរៀងដោយ
**ឯកឧត្តម ងី ច័ន្ទផល**
រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
អនុប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ

library.ncdd.gov.kh
014181

ភ្នំពេញ
ខែមិថុនា ឆ្នាំ២០១៣

# មាតិកា


១. កំណើនសេដ្ឋកិច្ចក្នុងបរិបទកម្ពុជា ....................

២. យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាព ....................

៣. យុទ្ធសាស្ត្រជាតិគាំពារសង្គមក្នុងតួនាទីប្រតិបត្តិកម្មលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ....................

៣.១ គោលដៅទាំង៥នៃយុទ្ធសាស្ត្រជាតិគាំពារសង្គម ....................

៣.២. ការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម ....................

៤. ទស្សនាទាននៃ "សមធម៌សង្គម" ....................

៥. ស្ថានភាពនៃភាពក្រីក្រ និងក្រុមជនងាយរងគ្រោះ ....................

៦. ការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គមដើម្បីលើកកម្ពស់សមធម៌ ....................

៦.១. ការសម្របសម្រួលការរៀបចំយុទ្ធសាស្ត្រជាតិគាំពារសង្គម ....................

៦.១.១ ការលើកកម្ពស់សមធម៌តាមរយៈការរៀបចំកម្មវិធីគាំពារសង្គម ....................

៦.១.២ សកម្មភាពក្នុងការលើកកម្ពស់សមធម៌តាមរយៈការរៀបចំកម្មវិធីគាំពារសង្គម ....................

៦.២. ការសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម ....................

៦.២.១ ការលើកកម្ពស់សមធម៌តាមរយៈការអនុវត្តកម្មវិធីគាំពារសង្គម ....................

៦.២.២ សកម្មភាពក្នុងការលើកកម្ពស់សមធម៌តាមរយៈការអនុវត្តកម្មវិធីគាំពារសង្គម ....................

៧. សេចក្តីសន្និដ្ឋាន ....................

៨. ឯកសារពិគ្រោះ ....................

# ការគាំពារសង្គម ដើម្បីកំណើនសេដ្ឋកិច្ច
# ប្រកបដោយសមធម៌ ក្នុងបរិបទកម្ពុជា

*... "យើងអភិវឌ្ឍន៍ដើម្បីឱ្យសង្គមនៃជាតិយើងមានឈ្មោះថា សង្គមមានសេចក្តីចំរើន មានការជឿនលឿន មានប្រយោជន៍ខ្ពស់ ខាងផ្លូវសំភារៈផង ខាងគំនិតបញ្ញាផង ទាំងខាងធម្មៈផង។ ជាតិណាក៏ដោយ សង្គមណាក៏ដោយ ដែលអាចចំរើនរុងរឿងបាន ត្រូវមានលក្ខណៈ៤ប្រការនេះ គឺ : ទី១-មនុស្សក្នុងសង្គមមានសមត្ថភាពគ្រប់វិស័យ ទី២- មនុស្សក្នុងសង្គមមានសេរីភាពពេញបរិបូណ៌ ទី៣- សង្គមមានរបបគ្រប់គ្រងប្រកបដោយយុត្តិធម៌ និងទី៤- បុគ្គលក្នុងសង្គម មានព្រហ្មវិហារធម៌ដល់គ្នានិងគ្នាជានិច្ច" ...*

*ព្រះគិត្តធម្មបាល ខៀវ ជុំ (១៩៧២)*

## ១. កំណើនសេដ្ឋកិច្ចក្នុងបរិបទកម្ពុជា

ទោះបីស្ថានភាពសេដ្ឋកិច្ចកម្ពុជា មានការប្រឈមដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក ព្រមជាមួយ និងផលប៉ះពាល់ដោយសារឥទ្ធិពលនៃការប្រែប្រួលធាតុអាកាស ទឹកជំនន់ និងការរាំងស្ងួតយ៉ាងណាក៏ដោយ កម្ពុជាបានធ្វើឱ្យសម្រេចជោគជ័យលើគ្រប់វិស័យទាំងខាងនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងការបរទេស នៅក្នុងដំណើរការអភិវឌ្ឍន៍របស់ខ្លួន។ កម្ពុជារក្សាបាននូវស្ថិរភាពនយោបាយ ស្ថិរភាពសង្គម ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពហិរញ្ញវត្ថុ ការពារបានរឹងមាំនូវអធិបតេយ្យបូរណភាពទឹកដី សន្តិសុខ និងសុវត្ថិភាពសង្គម នៅក្នុងពេល និងក្រោយពេលមានវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិភពលោក ព្រមទាំងវិបត្តិព្រំដែនកម្ពុជា-ថៃ និងគ្រោះទឹកជំនន់។

**ប្រទេសកម្ពុជាបានឆ្លងច្រើនដំណាក់កាលនៃការអភិវឌ្ឍន៍ (សង្គ្រាមបន្ទាន់ ការស្តារនីតិសម្បទា និងការអភិវឌ្ឍន៍) ហើយបានទើបផុតឡើងក្រោយពីបានជួបវិបត្តិជាច្រើនទស្សវត្សរ៍កន្លងមក** និងសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាលើ១០% រយៈពេលបួនឆ្នាំជាប់ៗគ្នា មកដល់ឆ្នាំ២០០៧។ អត្រានៃភាពក្រីក្រ បាន

ធ្លាក់ពី៤៧% នៅឆ្នាំ១៩៩៣/១៩៩៤ មកត្រឹម២៦%នៅឆ្នាំ២០១០។ កំណើនសេដ្ឋកិច្ច គិតជាផលិតសរុបក្នុងស្រុកមានការកើនឡើងទ្វេដងក្នុងរយៈពេល១០ឆ្នាំ (១៩៩៤-២០០៤) និងកើនឡើង៣ដងក្នុងរយៈពេល១៥ឆ្នាំ (១៩៩៤-២០០៩)។

កំណើនសេដ្ឋកិច្ចក្នុងចន្លោះឆ្នាំ២០០៨-២០១២ សម្រេចបាន៥,៦%ក្នុងមួយឆ្នាំ។ ប៉ុន្តែបើមិនរាប់បញ្ចូលកំណើនឆ្នាំ២០០៩ ដែលជាឆ្នាំនៃការស្រុតចុះដោយសារវិបត្តិសេដ្ឋកិច្ចសកលលោក កំណើនសេដ្ឋកិច្ចនៅកម្ពុជា សម្រេចបានជាមធ្យម៦,៨%។ នៅឆ្នាំ២០១២ កំណើនឡើង៧,៣%។ **ផលិតផលក្នុងស្រុក (ផសស) សម្រាប់មនុស្សម្នាក់បានកើនឡើងពី៧៦០ដុល្លារនៅឆ្នាំ២០០៨ មកជិត១០០០ដុល្លារនៅឆ្នាំ២០១២ និងអាចកើនឡើងដល់១០៨០ដុល្លារនៅឆ្នាំ២០១៣**។ កម្ពុជានឹងងើបចេញពីចំណោមក្រុមប្រទេសក្រីក្រ មកជាចំណាត់ថ្នាក់ **"ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប"**។ អត្រានៃភាពក្រីក្របានធ្លាក់មកត្រឹមតែ២០%នៅឆ្នាំ២០១២ និងអាចដល់១៩%នៅឆ្នាំ២០១៣ **(Hang Chuon Naron, 2013)**។ កម្ពុជាអាចសម្រេចបាន **គោលដៅអភិវឌ្ឍសហស្សវត្សរ៍ទី១** គឺការកាត់បន្ថយអត្រានៃភាពក្រីក្រឱ្យបានពាក់កណ្ដាល។ ប្រការនេះញ៉ាំងឱ្យកម្ពុជាទទួលបាននូវការ វាយតម្លៃថាជាប្រទេសស្ថិតនៅក្នុងចំណាត់ថ្នាក់ទី១៥ ដែលទទួលបាននូវកំណើនសេដ្ឋកិច្ចខ្ពស់លើពិភពលោក ក្នុងរយៈពេល១០ឆ្នាំជាប់ៗគ្នាចុងក្រោយនេះ និងជាប្រទេសស្ថិតក្នុងចំណាត់ថ្នាក់ទី៥ ក្នុងចំណោមក្រុមប្រទេសកំពុងអភិវឌ្ឍន៍ ដែលនឹងសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សមុនឆ្នាំ២០១៥ ព្រមទាំងជាប្រទេសស្ថិតក្នុងចំណាត់ថ្នាក់ទី១នៅអាស៊ី-ប៉ាស៊ីហ្វិក ដែលសម្រេចបាននូវល្បឿនក្នុងការកែលម្អសូចនាករផ្នែកសង្គមកិច្ច (សម្ដេចតេជោ ហ៊ុន សែន, ២០១៣ក)។

ក្នុងក្របខណ្ឌនៃការ **អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គម**[1] នៅឆ្នាំ២០១២ រាជរដ្ឋាភិបាលបានបន្តជំរុញអនុវត្តប្រកបដោយប្រសិទ្ធភាព នូវរាល់កំណែទម្រង់ស៊ីជម្រៅរបស់ខ្លួន ជាពិសេសការលុបឡូតិ៍នេសាទទឹកសាបនៅទូទាំងប្រទេស (ថ្ងៃទី៨ ខែមិនា ២០១២) ដើម្បីប្រគល់ជូនប្រជាជនធ្វើការនេសាទជាលក្ខណៈគ្រួសារ និងអភិរក្សជលផល ការផ្អាកការផ្ដល់ដីសម្បទានសេដ្ឋកិច្ចបន្ថែមទៀត ព្រមទាំងការ

---

[1] ពាក្យ **ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច** សំដៅលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (មានផ្លូវគមនាគមន៍ ថាមពល ប្រព័ន្ធធារាសាស្ត្រ) ពាណិជ្ជកម្មក្នុងស្រុកនិងនាំចេញ វិនិយោគ ធនាគារ សហគ្រាសខ្នាតតូច សាជីវកម្មសេវា និងមូលដ្ឋានសេដ្ឋកិច្ច (មានកសិកម្ម ទេសចរណ៍ ឧស្សាហកម្ម ធនធានរ៉ែ ការងារ មុខរបរ និងធនធានមនុស្ស) ជាដើម។ **ហេដ្ឋារចនាសម្ព័ន្ធសង្គម** សំដៅលើការងារ វិស័យសុខាភិបាល វិស័យអប់រំ វិស័យសង្គមកិច្ច មូលធនមនុស្ស ការគាំពារសង្គម ។ល។

អនុវត្ត "**នយោបាយចាស់ សកម្មភាពថ្មី**" លើវិស័យដីធ្លី ដើម្បីវាស់វែង និងផ្តល់កម្មសិទ្ធិ ដីធ្លី លំនៅឋាន និងដីស្រែចំការជូនប្រជាជន និងកសិករជាអ្នកកាន់កាប់ប្រើប្រាស់ដីជាក់ស្តែង ដែលគ្របដណ្តប់លើផ្ទៃដីប្រមាណ ២លានហិកតា និងមានប្រជាជនជិត៥០ម៉ឺនគ្រួសារ ដែលត្រូវទទួលបានប័ណ្ណកម្មសិទ្ធិ (ថ្ងៃទី៧ ខែឧសភា ២០១២)។ **យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ** ត្រូវបានដាក់ចេញឱ្យអនុវត្ត (ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១១) ក្នុងគោលបំណងគាំទ្រដល់ជនក្រីក្រឱ្យអាចចាកផុតពីភាពក្រីក្រ និងប្រែក្លាយជនក្រីក្រនិងជនងាយរងគ្រោះ និងសហគមន៍កម្ពុជាឱ្យទៅជាកម្លាំងមូលដ្ឋានផលិតរបស់ជាតិទាំងមូល និងចូលរួមចំណែកយ៉ាងសកម្មជាចលនាឋាមវន្តក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា។ អនុក្រឹត្យស្តីពីការបង្កើត "**ប្រព័ន្ធស្បៀងបម្រុងកម្ពុជា**" ត្រូវបានអនុម័ត ដើម្បីត្រៀមផ្គត់ផ្គង់ស្បៀងនិងគ្រាប់ពូជបម្រុង ដើម្បីជួយសង្គ្រោះប្រជាពលរដ្ឋរងគ្រោះដោយសារគ្រោះមហន្តរាយ ឬគ្រោះអាសន្ន នានាឱ្យទាន់ពេលវេលា (អនុក្រឹត្យលេខ១៤៥អនក្រ.បក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២)។ កំណែទម្រង់ធំៗ ទាំងនេះ មានចរិត**ប្រជាធិបតេយ្យប្រជាជន** យ៉ាងជ្រាលជ្រៅដែលបានបង្ហាញឱ្យឃើញច្បាស់នូវនយោបាយ និងការអនុវត្តរបស់រាជរដ្ឋាភិបាល ដើម្បីផលប្រយោជន៍របស់ប្រជាជន។

ក្នុងក្របខណ្ឌនៃការ **អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធប្រជាធិបតេយ្យ**[២] កំណែទម្រង់ស៊ីជម្រៅត្រូវបានបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សត្រូវបានពង្រឹងនិងពង្រីក កិត្តិយសនិងកិត្តិនាមរបស់កម្ពុជាត្រូវបានលើកកម្ពស់លើឆាកអន្តរជាតិ ហើយកំណើនសេដ្ឋកិច្ចមានការកើនឡើងជាបន្តបន្ទាប់។ ក្នុងឆ្នាំ ២០១២ កម្ពុជាបានរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៣ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៣ ដោយជោគជ័យ ប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដែលបានបង្ហាញច្បាស់ថាលទ្ធិប្រជាធិបតេយ្យកំពុងត្រូវបានពង្រឹងនិងពង្រីកដោយឥតឈប់ឈរ។

---

២ **ហេដ្ឋារចនាសម្ព័ន្ធប្រជាធិបតេយ្យ** ឬម្យ៉ាងហៅថា **ហេដ្ឋារចនាសម្ព័ន្ធអរូបិយ** គឺជាសកម្មភាពការងារ ដែលមិនរាប់បញ្ចូលក្នុងវិស័យសេដ្ឋកិច្ច ឬវិស័យសង្គមកិច្ច ប៉ុន្តែគឺជាវិស័យសំខាន់មិនអាចខ្វះបានក្នុងការធានាការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ចប្រកបដោយចិរភាព មានជាអាទិ៍ ធានាបាននូវស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម ថែរក្សាការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ការពង្រឹងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងមានការបោះឆ្នោតជាដើម។ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ការអនុវត្តគោលការណ៍និងយន្តការអភិបាលកិច្ចល្អដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ការពង្រឹងគណនេយ្យភាពសង្គម ការផ្តល់សេវារដ្ឋបាលនិងសាធារណៈ ការដោះស្រាយទំនាស់នៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការជាដើម ។ល។ សុទ្ធសឹងតែជាសកម្មភាពដែលចាំបាច់ និងជាកត្តាជោគជ័យនៃការអភិវឌ្ឍន៍ ប្រកបដោយចិរភាព និងអាចងើបផុតពីអន្ទាក់នៃប្រទេសមានប្រាក់ចំណូលមធ្យម (Middle Income Traps)។

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវ***គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ*** គឺដើម្បីបម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង។ នេះគឺជាគោលដៅយុទ្ធសាស្ត្រ និងជាត្រីវិស័យក្នុងការអនុវត្តការដ្ឋានកំណែទម្រង់ជាអាទិភាពរបស់រាជរដ្ឋាភិបាល ដែលបានលើកឡើងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២។ នៅក្នុងការពង្រឹងអភិបាលកិច្ចល្អដែលជាស្នូលនៃយុទ្ធសាស្ត្រ ដំណើរការកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដែលមានគោលដៅពង្រឹងអភិបាលកិច្ចនៅមូលដ្ឋាននិងការផ្តល់សេវាសាធារណៈបានផ្តល់ឱកាសថ្មីៗថែមទៀតសម្រាប់លើកកម្ពស់គោលការប្រជាធិបតេយ្យភាព បង្កើនកាលានុវត្តភាពនៃការអភិវឌ្ឍន៍ កាត់បន្ថយភាពក្រីក្រ និងធានាស្ថិរភាព សមធម៌ និងការចូលរួមក្នុងការអភិវឌ្ឍន៍[៣]។

ឆ្លងតាមព្រឹត្តិការណ៍ដែលបានកើតឡើងសំខាន់ៗ ឆ្នាំ២០១២ចាត់ជាឆ្នាំពិសេសរបស់កម្ពុជា ដែលត្រូវកត់ត្រាទុកជាប្រវត្តិសាស្ត្រនៃការអភិវឌ្ឍន៍ប្រទេស ឆ្ពោះទៅកាន់ភាពចម្រុងចម្រើនរុងរឿងលើគ្រប់វិស័យក្នុងសម័យសម្តេចអគ្គមហាសេនាបតីតេជោ នៃសតវត្សទី២១នេះ ជាពិសេសក្នុងរយៈពេល៦០ឆ្នាំចុងក្រោយ និងជាឆ្នាំមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍន៍ច្រើនទសវត្សទៅអនាគត។ **កម្ពុជាកំពុងស្ថិតនៅចំណុចដ៏សំខាន់ក្នុងដំណើរការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងរំកិលបន្តិចម្តងៗឈានពីប្រទេសអភិវឌ្ឍន៍តិចតួច នៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥-២០១៦** (សម្តេចតេជោ ហ៊ុន សែន, ២០១៣ក)។ នៅឆ្នាំ២០២០ សេដ្ឋកិច្ចនៅកម្ពុជាអាចកើនឡើងទ្វេដងថែមទៀត ការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចមានការរីកចម្រើនឈានទៅកាត់បន្ថយអត្រាភាពក្រីក្របានមួយកម្រិតទៀត។

---

[៣] **ក្រសួងមហាផ្ទៃ** ជាក្រសួងនាំមុខ មានតួនាទីនិងភារកិច្ចយ៉ាងសំខាន់ក្នុងការសម្របសម្រួល សហការ ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ជម្រុញលើកកម្ពស់ការអនុវត្តគ្រប់ជ្រុងជ្រោយ ក្នុងការបន្តរក្សាយ៉ាងគត់ហ្មត់នូវសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ ពង្រឹងស្ថិរភាពនយោបាយ ស្ថិរភាពសង្គម បន្តជម្រុញគោលនយោបាយ **"ភូមិ-ឃុំមានសុវត្ថិភាព"** ជម្រុញការអនុវត្តកម្មវិធីកំណែទម្រង់សម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ ក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងបន្តជំរុញដំណើរការ**ប្រជាធិបតេយ្យភាវូបនីយកម្ម** ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទាំងក្នុងវិស័យ នយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច ឱ្យឈានឡើងឥតឈប់ឈរនៅក្នុងបរិការណ៍របស់កម្ពុជា លើមូលដ្ឋាននៃការបន្តលើកកម្ពស់នីតិរដ្ឋ ការលើកស្ទួយសិទ្ធិសេរីភាពស្របច្បាប់របស់ប្រជាពលរដ្ឋ ការធានានូវសកម្មភាពដោយសេរីរបស់គណបក្សនយោបាយ ការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ ព្រមទាំងការលើកកម្ពស់សុខុមាលភាពសង្គម។ កម្ពុជានឹងបន្តអនុវត្តយ៉ាងសកម្មនូវរាល់កំណែទម្រង់រដ្ឋដ៏ស៊ីជម្រៅ ដែលបាននិងកំពុងអនុវត្ត ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អនៅគ្រប់ថ្នាក់ គ្រប់ផ្នែក បង្កើនជំនឿរបស់ប្រជាជនចំពោះការដឹកនាំរបស់រាជរដ្ឋាភិបាល និងខិតខំអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពនូវការប្រឆាំងអំពើពុករលួយ ជាពិសេសការលុបបំបាត់ការយកកម្រៃខុសច្បាប់លើការផ្តល់សេវារដ្ឋបាលនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រប់ថ្នាក់ ដោយអនុវត្តឱ្យបានហ្មត់ចត់នូវខ្លឹមសារអនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០១៣។

## ២. យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាព

**ទិសដៅជាសារវន្តរបស់រាជរដ្ឋាភិបាលកម្ពុជា គឺកសាងជាជំហានៗនូវសង្គមកម្ពុជាមួយដែលមានសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខនិងសណ្តាប់ធ្នាប់សង្គម មានការអភិវឌ្ឍន៍ប្រកបដោយចីរភាពនិងសមធម៌** ជាមួយនឹងការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស និងការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស ជាសង្គមមួយដែលមានកោសិកាផ្សារភ្ជាប់គ្នា មានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់ និងវប្បធម៌ជ្រៅជ្រះ មានជីវភាពសមរម្យ និងមានការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងសង្គមជាតិ ទាំងក្នុងក្រុមគ្រួសារ។ **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២** ដែលជាការបន្តអនុវត្ត **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១** នឹងដែលបានបន្តពី **យុទ្ធសាស្ត្រត្រីកោណ** គឺជាយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលនីតិកាលទី៤នៃរដ្ឋសភា ដែលរៀបចំឡើងតាមរចនាសម្ព័ន្ធមុំបួននៃចតុកោណប្រទាក់ក្រឡាគ្នា ហើយផ្សារភ្ជាប់គ្នាគ្រប់ជ្រុងទាំងអស់នៅក្នុងផ្ចិតគំនិតរបស់មនុស្សទូទៅ គឺតំណាងឱ្យ **"ចីរភាពនិងស្ថិរភាព"** ដែលរឹងមាំ។ ក្នុងន័យនេះ ការសម្រេចបានជោគជ័យនៅក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណ នឹងនាំមកឱ្យកម្ពុជានូវស្ថិរភាព និងការអភិវឌ្ឍប្រកបដោយចីរភាពនិងសមធម៌។

គោលដៅចំបងរបស់យុទ្ធសាស្ត្រចតុកោណ គឺជំរុញលើកកំពស់កំណើនសេដ្ឋកិច្ច ការដោះស្រាយការងារសំរាប់ពលករកម្ពុជា ការធានាសមធម៌និងយុត្តិធម៌សង្គម និងការលើកស្ទួយប្រសិទ្ធភាពវិស័យសាធារណៈ តាមរយៈផែនការសកម្មភាពអភិបាលកិច្ចនិងកំណែទំរង់ស៊ីជំរៅ និងប្រទាក់ក្រឡាគ្នា ក្នុងគ្រប់ផ្នែកគ្រប់វិស័យ ដោយកំណត់បាវចនានៃការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលនីតិកាលទី៤ នៃរដ្ឋសភានេះ ថាជា **"រាជរដ្ឋាភិបាលដើម្បី កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព "**។

ដើម្បីសម្រេចបានតាមទិសដៅនេះ **យុទ្ធសាស្ត្រចតុកោណ** បានដាក់ចេញនូវគោលដៅ៤យ៉ាង ដែលស្តែងចេញ តាមរយៈបាវចនា **កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព**។ ក្នុងន័យនេះ យុទ្ធសាស្ត្រចតុកោណគឺជាយុទ្ធសាស្ត្រ អភិវឌ្ឍរយៈពេលវែង ដែលផ្អែកលើគោលនយោបាយជាមូលដ្ឋានគ្រឹះដូចខាងក្រោម :

- ទី១. ការធានានូវចីរភាពនៃសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម តាមរយៈវិធានការជាក់ស្តែងនានា សំដៅលើកស្ទួយនីតិរដ្ឋការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូរ

របស់មនុស្ស និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដើម្បីបង្កើតឡើងនូវបរិស្ថាននយោបាយ និងសន្តិសុខ ដែលអនុគ្រោះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពក្នុងរយៈពេលវែង

- ទី២. ការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងរយៈពេលវែង មានអត្រាខ្ពស់ប្រមាណ៧%ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អត្រាអតិផរណាទាបក្នុងកម្រិតតួលេខមួយខ្ទង់ អត្រាប្តូរប្រាក់មានស្ថិរភាព និងមានកំណើនទុនបម្រុងជាប្រចាំ
- ទី៣. ការធានាបែងចែកប្រកបដោយសមធម៌នូវកាលានុវត្តភាព និងផ្លែផ្កានៃកំណើនសេដ្ឋកិច្ច
- ទី៤. ការធានាចីរភាពនៃបរិស្ថាន ជាពិសេសតាមរយៈការគ្រប់គ្រង និងប្រើប្រាស់ប្រកបដោយចីរភាព នូវធនធានធម្មជាតិ ។

**ការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ គឺជាការបន្តសកម្មភាពពង្រីកនូវសមិទ្ធផលនានា ដែលរាជរដ្ឋាភិបាលសម្រេចបានក្នុងរយៈពេលកន្លងមកដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហវត្សរ៍** ក្នុងទិសដៅកែលម្អនិងបង្កើនសមត្ថភាពរបស់ស្ថាប័នសាធារណៈ លើកស្ទួយអភិបាលកិច្ចល្អ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិសំដៅលើកកម្ពស់កំណើនសេដ្ឋកិច្ច បង្កើតការងារជូនប្រជាពលរដ្ឋ ធានាសមធម៌ក្នុងសង្គម និងបង្កើនប្រសិទ្ធភាពនៃវិស័យសាធារណៈ ព្រមទាំងរក្សាការពារសម្បត្តិធម្មជាតិ និងសម្បត្តិវប្បធម៌ជាតិ ដែលទាំងអស់នេះគឺសុទ្ធតែជាកត្តាគន្លឹះដ៏សំខាន់បំផុតសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ក្នុងក្របខណ្ឌនៃទស្សនៈនេះ តម្រូវឱ្យរាជរដ្ឋាភិបាលបន្តសម្រិតសម្រាំង កែលម្អ និងពង្រឹងអាទិភាពគោលនយោបាយ បន្តកែលម្អនូវយុទ្ធសាស្ត្រតាមផ្នែក ឱ្យឆ្លុះបញ្ចាំងនូវសភាពការណ៍ជាក់ស្តែងរបស់កម្ពុជា ដោយឈរលើបទពិសោធន៍ជាក់ស្តែងនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ សម្រាប់នីតិកាលទី៣ នៃរដ្ឋសភាក្នុងពេលកន្លងមក (រាជរដ្ឋាភិបាលកម្ពុជា, ២០០៨) ។

**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២** ត្រូវបានរៀបចំ និងក្លាយជាមូលដ្ឋានគ្រឹះនៃគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ហើយត្រូវបានចាត់ទុកថាជា **របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ចនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល** សម្រាប់នីតិកាលទី៤នៃរដ្ឋសភា។ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ** គឺជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ (រាជរដ្ឋាភិបាលកម្ពុជា, ២០០៩)។ **ផែនការ**

យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ត្រូវបានរៀបចំឡើង ដើម្បីសម្រេចឱ្យបាននូវគោលដៅអាទិភាពចំនួនពីរ គឺ :

- គោលដៅទី១ ដើម្បីបន្សីអណត្តិកាលរបស់ឯកសារយុទ្ធសាស្ត្រនេះ ជាមួយអាណត្តិកាលរបស់រាជរដ្ឋាភិបាល សំដៅធានាថាសកម្មភាពដែលបានគ្រោងទុកទាំងឡាយរបស់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវបានរៀបចំឡើង ដើម្បីអនុវត្តគោលយោបាយអាទិភាពទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២
- គោលដៅទី២ គឺដើម្បីធានាថាការងារដែលត្រូវបានលើកឡើងដោយក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងនេះ ត្រូវបានរៀបចំឡើងដោយមានការគិតគូរដល់ផលប៉ះពាល់នៃការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោក ដែលអាចមានមកលើសេដ្ឋកិច្ចជាតិ ។

## ៣. បញ្ហាប្រឈម

ថ្លែងក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រីលើកទី១សម្រាប់នីតិកាលទី៤នៃរដ្ឋសភា នៅទីស្តីការគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០០៨ **សម្តេចតេជោ** បានលើកឡើងពីបញ្ហាប្រឈម១៧ចំណុចរបស់រាជរដ្ឋាភិបាល ទោះបីជាបានទទួលជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ក៏ដោយ ដែលរាជរដ្ឋាភិបាលត្រូវបន្តដោះស្រាយក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ដោយបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ។

**កំណើន** : ទោះបីជាក្នុងរយៈពេលកន្លងមក តាមរយៈកំណើនសេដ្ឋកិច្ចខ្ពស់ និងការអនុវត្តគោលនយោបាយគាំទ្រកំណើនសំខាន់ក៏ដោយ ក៏អត្រាភាពក្រីក្រនៅតែមានកម្រិតខ្ពស់នៅឡើយ ។ លើសពីនេះគម្លាតរវាងអ្នកមាននិងអ្នកក្រ ពិសេសវិសមភាពរវាងទីក្រុង តំបន់ទីប្រជុំជន និងតំបន់ជនបទ នៅបន្តស្ថិតនៅជាបញ្ហាប្រឈមនៅឡើយ ។

**ការងារ** : កង្វះខាតអ្នកបច្ចេកទេស និងពលករជំនាញ នៅតែជាឧបសគ្គដ៏ធ្ងន់ធ្ងរមួយនៅក្នុងការខិតខំពន្លឿន ការអភិវឌ្ឍសេដ្ឋកិច្ចទាំងនៅទីក្រុង ទាំងនៅទីជនបទ ។ គ្រាន់តែក្នុងវិស័យដំណាំកៅស៊ូនាបច្ចុប្បន្ន ដីដែលដាំហើយមានចំនួន៣សែនហិកតា និងប្រើប្រាស់កម្មករចំនួន១សែននាក់ ។ ៥ឆ្នាំទៀតចំការកៅស៊ូ ត្រូវបានដាំដុះនិងប្រមូលផលលើផ្ទៃដីជាង៨សែនហិកតា ដោយគ្រោងប្រើកម្មករប្រមាណ១,៣លាននាក់ ភាគច្រើននៃផ្ទៃដីដាំដុះស្ថិតនៅក្នុងភូមិភាគតំបន់ឥសាន្តនិងមានប្រជាពលរដ្ឋតិចរស់នៅ ។

ដោយឡែកយោងតាមរបាយការណ៍ ពីស្ថានទូតកម្ពុជានៅថៃបានឱ្យដឹងថា អាជ្ញាធរថៃបានចុះបញ្ជីពលករខ្មែរខុសច្បាប់ចំនួន២៤២.៤២៩នាក់[៤]។ ការធ្វើទេសន្តរប្រវេសន៍របស់ពលករកម្ពុជា នៅតែជាបញ្ហាប្រឈមនៅឡើយ ទោះបីជាមានរបាយការណ៍ថាពលករទទួលបានប្រាក់ចំណូលតាមការសន្យារបស់ក្រុមហ៊ុនក៏ដោយ ព្រោះជាក់ស្តែងពលករជាច្រើនមិនបានទទួលប្រាក់កម្រៃការងារពេញលេញតាមរំពឹងទុកនោះឡើយ ហើយក៏កំពុងប្រឈមនឹងបញ្ហាដែលគួរព្រួយបារម្ភផងដែរ ពាក់ព័ន្ធនឹងសុវត្ថិភាព ការរំលោភសិទ្ធិ សេចក្តីថ្លៃថ្នូររបស់ពលករ និងកិត្តិយសប្រទេសជាតិ។

**សមធម៌ :** កិច្ចការពារសុវត្ថិភាពសង្គម ជាពិសេសសម្រាប់ពលករ ជនក្រីក្រ និងជនងាយរងគ្រោះនៅមិនទាន់មានលក្ខណៈជាប្រព័ន្ធនៅឡើយ។ នៅក្នុងវិស័យសុខាភិបាល យើងសម្រេចបានលទ្ធផលជាវិជ្ជមានជាច្រើន តែការផ្តល់សេវាសុខាភិបាលសាធារណៈប្រកបដោយគុណភាពនៅមានកម្រិត ហើយអត្រាមរណមាតានៅមានកម្រិតខ្ពស់។ សេវាថែទាំសុខភាពនិងអនាម័យជនបទ រួមទាំងការផ្គត់ផ្គង់ទឹកស្អាតជនបទសម្រេចបានក្នុងកម្រិតទាបនៅឡើយ បើប្រៀបធៀបទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍[៥]។ យោងតាមទិន្នន័យ**អង្កេតប្រជាសាស្ត្រនិងសុខភាព** និង**ការអង្កេតមនុស្សមាត្រ** ក្នុងឆ្នាំ២០០៨ បានបង្ហាញពីភាពនៅទ្រឹងនៃសូចនាករអាហារូបត្ថម្ភ ដែលឆ្លុះបញ្ចាំងពីភាពកង្វះអាហារូបត្ថម្ភចំពោះទារកនិងកុមារ។ អត្រាស្គមស្គាំងកុមារអាយុក្រោម៥ឆ្នាំ បានកើតឡើងពី ៨.៤% (២០០៥) ដល់ ៨.៩%(២០០៨) និង ១០.៩% (២០១០)។ ភាពក្រិសក្រិន និងខ្វះទម្ងន់ហាក់ដូចជានៅទ្រឹង រវាងឆ្នាំ២០០៥ មកឆ្នាំ២០១០។ សូចនាករទាំងបីនៃកង្វះអាហារូបត្ថម្ភរបស់កុមារ មានការខុសគ្នាពីតំបន់មួយទៅតំបន់មួយក្នុងប្រទេសកម្ពុជា។ ម្យ៉ាងវិញទៀត លទ្ធផលនៃការអង្កេតក៏បានបញ្ជាក់ស្ថានភាពអាហារូបត្ថម្ភរបស់មាតា ក៏មិនសូវល្អប្រសើរដែរក្នុងចន្លោះឆ្នាំ ២០០៥ និង២០១០។

**ប្រសិទ្ធភាព :** ទោះបីជាការងារកែទម្រង់រដ្ឋសំខាន់ៗ សំដៅធានាពង្រឹងអភិបាលកិច្ចល្អសម្រេចបានជោគជ័យគួរជាទីកត់សម្គាល់មួយចំនួនក៏ដោយ ក៏ប៉ុន្តែបញ្ហាប្រឈមនៅតែមាន ជាអាទិ៍ គុណភាព

---

[៤] របាយការណ៍ការសិក្សាអំពីទេសន្តរប្រវេសន៍នៅកម្ពុជា របស់គណៈកម្មាធិការដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ (ប.ជ.រ.ព.ភ.) ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ គាំទ្រដោយ **USAID and WINROCK**

[៥] យោងឯកសារ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ (២០០៨-២០១៣) - សេចក្តីថ្លែងការថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨

ប្រសិទ្ធភាព និងការផ្តល់សេវាសាធារណៈនៅមានកម្រិត មិនទាន់អាចឆ្លើយតបបានទៅនឹងតម្រូវការចាំបាច់ជាក់ស្តែង។ អត្រានៃការធ្វើជំនួញ ឬធុរៈកិច្ចនៅកម្ពុជាមានចំណាត់ថ្នាក់១៤៧ លើប្រទេស១៨៣ ប្រៀបធៀបជាមួយប្រទេសចិន (៧៩) វៀតណាម (៧៨) ម៉ាឡេស៊ី (២១) និងថៃ (១៩)។ ក្រុមហ៊ុនដែលមានបំណងធ្វើពាណិជ្ជកម្មរកស៊ីនៅកម្ពុជា ត្រូវបំពេញបែបបទស្មុគស្មាញ ត្រូវប្រើពេលយូរ នៅមានភាពសាំញ៉ាំ ប្រើពេលវែង តម្លៃខ្ពស់ **CDRI (2012)**។

**រាជរដ្ឋាភិបាលទទួលស្គាល់ថា កម្ពុជានៅមានផ្លូវដ៏វែងឆ្ងាយសំរាប់ធ្វើដំណើរទៅមុខ ហើយត្រូវពុះពារឆ្លងកាត់ឧបសគ្គរាប់មិនអស់ថែមទៀត ដើម្បីសំរេចបាននូវចីរភាព និងវិបុលភាពដ៏រុងរឿងថ្កើនថ្កាន ជូនប្រទេសជាតិ។** ក្នុងន័យនេះការខិតខំដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅតែជាគោលដៅដ៏ចំបងបំផុតរបស់រាជរដ្ឋាភិបាល។ ពិតណាស់ រាជរដ្ឋាភិបាលទទួលស្គាល់ថាគ្រប់បញ្ហានៃភាពក្រីក្រ ពុំអាចនឹងត្រូវបានដោះស្រាយក្នុងរយៈពេលតែមួយថ្ងៃ ឬមួយខែ ឬមួយឆ្នាំនោះឡើយ។ ក៏ប៉ុន្តែដោយមានកម្មវិធីនយោបាយច្បាស់លាស់ និងដោយមានកិច្ចខិតខំប្រឹងប្រែងរួមគ្នា កម្ពុជាប្រាកដជានឹងអាចធ្វើឱ្យមានការវិវត្តជាវិជ្ជមានយ៉ាងច្រើននៅក្នុងការលើកស្ទួយកំរិតជីវភាពរបស់ប្រជាជន តាមរយៈកំណែទម្រង់ខាងលើនេះ។

## ៤. យុទ្ធសាស្ត្រជាតិគាំពារសង្គម ក្នុងតួនាទីប្រតិបត្តិកម្មលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ

### ៤.១ អតិក្រម វិសាលភាព និងទស្សនវិស័យ

**ការគាំពារសង្គម គឺជាការឧបត្ថម្ភដែលផ្តល់ទៅដល់ប្រជាជន ដើម្បីឆ្លើយតបទៅនឹងបញ្ហាជាឫសគល់ នៃភាពក្រីក្រនិងភាពងាយរងគ្រោះ ព្រមទាំងដើម្បីបង្កើនការអភិវឌ្ឍធនធានមនុស្សក្នុងពេលជាមួយគ្នា**។ ការគាំពារសង្គមរួមបញ្ចូលនូវការរៀបចំ និងការប្រើប្រាស់ឧបករណ៍ជាច្រើនប្រភេទ ដើម្បីការពារបុគ្គល គ្រួសារ និងសហគមន៍ ពីប្រភេទ ផ្សេងៗនៃផលវិបាកផ្នែកហិរញ្ញវត្ថុ សេដ្ឋកិច្ច និងសង្គមដែលកើតឡើងពីហានិភ័យ ឬវិបត្តិ ដើម្បីជួយពួកគាត់ឱ្យចាកផុតពីភាពក្រីក្រ។ អន្តរាគមន៍នៃការគាំពារសង្គមក្នុងកម្រិតអប្បបរមារួមមានការធានារ៉ាប់រងសង្គម គោលនយោបាយទីផ្សារពលកម្ម បណ្តាញសុវត្ថិភាពសង្គម និងសេវាកម្មសុខុមាលភាពសង្គម (រាជរដ្ឋាភិបាលកម្ពុជា, ២០១១)។ ការគាំពារសង្គម គឺជាការវិនិយោគសម្រាប់ការអភិវឌ្ឍន៍ជាតិ ជួយដល់ការកាត់បន្ថយភាពក្រីក្រ បង្កើនតម្រូវការ និងការពង្រីកទីផ្សារ និងជួយដល់ការ

កសាងធនធានមនុស្ស មានសុខភាពបរិបូណ៌ មានការសិក្សាចំណេះដឹងជំនាញខ្ពស់ និងមានកម្លាំងផលិតភាពគ្រប់គ្រាន់ ។

រូបទី១. វិសាលភាពនៃ យ.ជ.គ.ស. ដោយផ្តោតលើជនក្រីក្រ និងជនងាយរងគ្រោះ




ប្រឈមទៅនឹងស្ថានភាពងាយរងគ្រោះនៅកម្ពុជា ការអភិវឌ្ឍន៍ឈានឡើងទៅក្នុងដំណាក់កាលថ្មីនៃសាកលភាវូបនីយកម្ម និងការធ្វើសមាហរណកម្ម ទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន និងដើម្បីបន្តអនុវត្តកំណែទម្រង់រដ្ឋនានា ដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រចតុកោណ និងជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ និងមានស្ថេរភាព កម្ពុជាត្រូវការពង្រីកវិសាលភាពគ្រប់ដណ្តប់នៃការគាំពារសង្គម នឹងជួយដល់ការកាត់បន្ថយភាពក្រីក្រគោកយ៉ាក ជួយសម្រាលជនក្រីក្រ ក្នុងការឆ្លើយតបរាល់ហានិភ័យដែលអាចកើតឡើងឈានទៅបង្កើនធនធានមនុស្ស និងលើកកម្ពស់ផលិតភាព និងចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងសមធម៌ ។

នៅដើមឆ្នាំ២០០៩ ដើម្បីធានាការអភិវឌ្ឍន៍ប្រកបដោយសមធម៌ រាជរដ្ឋាភិបាលបានផ្តួចផ្តើមកិច្ចការ

វិភាគទូទៅក្នុងការកំណត់នូវវិសាលភាព នៃប្រព័ន្ធសុវត្ថិភាពសង្គមដែលមានស្រាប់ និងការកំណត់ទិសដៅគោលនយោបាយ ព្រមទាំងជម្រើសយុទ្ធសាស្ត្រសម្រាប់ការបង្កើតឡើងនូវប្រព័ន្ធសុវត្ថិភាពសង្គមមួយ ដែលមានលក្ខណៈចំរុះនិងជាប្រព័ន្ធ និងស្របតាមស្ថានភាពសង្គម-សេដ្ឋកិច្ចនៅកម្ពុជា។ ទស្សនាទាន និងចក្ខុវិស័យជាក្របខណ្ឌនៃ**យុទ្ធសាស្ត្រគាំពារសង្គមសម្រាប់គ្រួសារក្រីក្រ និងជនងាយរងគ្រោះ** បានត្រូវរៀបចំតាក់តែងឡើង ដោយមានការថ្លឹងថ្លែងរវាងដំណោះស្រាយ ដើម្បីការកាត់បន្ថយភាពក្រីក្រផងដែរ ជួយជនក្រីក្រឱ្យមានសមត្ថភាពឆ្លើយតបនូវហានិភ័យទាំងឡាយ ឬគ្រោះមហន្តរាយធម្មជាតិ និងបរិស្ថានផង ព្រមជាមួយការលើក កំពស់សមត្ថភាពធនធានមនុស្សដើម្បីអាចចៀសផុតពីភាពក្រីក្រ ដោយខ្លួនឯងនាពេលអនាគត។

**យ.ជ.គ.ស. ជាយុទ្ធសាស្ត្របំពេញបន្ថែមដល់យុទ្ធសាស្ត្រនិងផែនការតាមវិស័យដទៃទៀតនៃក្រសួងស្ថាប័នពាក់ព័ន្ធ ដែលជាប់ទាក់ទងដោយផ្ទាល់ ឬដោយប្រយោលទៅនឹងការគាំពារសង្គម**។ ឯកសារនេះមានភាពស្របគ្នា ព្រមទាំងធ្វើឱ្យមានសកម្មភាពប្រតិបត្តិការទៅលើអាទិភាពនានា ដែលមានចែងនៅក្នុងឯកសារយុទ្ធសាស្ត្រចតុកោណ និងឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣។ យ.ជ.គ.ស ត្រូវបានបង្កើតឡើងដោយ ឈរលើអភិក្រមសំខាន់ៗចំនួន៣ រួមមាន :

- ទី១. ការទ្រទ្រង់ជនក្រីក្របំផុតនិងជនដែលងាយរងគ្រោះបំផុត ហើយដែលពុំអាចមានលទ្ធភាពជួយខ្លួនឯងបាន តាមរយៈសេវាកម្មនិងការឧបត្ថម្ភសង្គម (ការផ្តល់សេវាកម្មសង្គម និងវប្បធម៌នៃការចែករំលែក ឧទាហរណ៍សកម្មភាពដ៏ឧត្តុង្គឧត្តមរបស់កាកបាទក្រហមកម្ពុជា)
- ទី២. ការកាត់បន្ថយផលប៉ះពាល់នៃហានិភ័យនិងវិបត្តិ ដែលអាចធ្វើឱ្យជនក្រីក្រនិងជនងាយរងគ្រោះ អាចប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយប្រកបដោយលក្ខណៈអវិជ្ជមាន (រួមមានការបញ្ឈប់កូនពីសាលារៀនដើម្បីទៅរកការងារធ្វើ ឬការលក់ដីស្រែចំការនិងទ្រព្យសម្បត្តិដើម្បីដោះស្រាយជីវភាពមួយគ្រា) តាមរយៈការផ្តល់សំណាញ់សុវត្ថិភាពសង្គមមូលដ្ឋាន (ការពិនិត្យព្យាបាលជំងឺដោយឥតគិតថ្លៃសម្រាប់ជនក្រីក្រ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ជាដើម)
- ទី៣. ការទ្រទ្រង់ដល់ជនក្រីក្រ ឱ្យបានឆ្លងផុតពីភាពក្រីក្រតាមរយៈការកសាងមូលធនមនុស្ស (ការអប់រំ សុខភាព និងជីវភាព) និងការពង្រីកកាលានុវត្តភាពរបស់ពួកគាត់ ។

ទស្សនវិស័យទូលំទូលាយនៃ យ.ជ.គ.ស. រួមបញ្ចូលគម្រោងការគាំពារសង្គម ដោយមានភាគទាន (ការធានារ៉ាប់រងសង្គម ឬរបបសន្តិសុខសង្គម) សម្រាប់និយោជិតនៃវិស័យឯកជននិងមន្ត្រីរាជការស៊ីវិល ហើយសំដៅឆ្ពោះទៅកាន់ការអភិវឌ្ឍមនុស្សក្នុងកម្រិតមួយខ្ពស់ ក៏ដូចជាជម្រើសការងារនិងកាលានុវត្តភាពដ៏សមស្របសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប : **"ប្រជាជនកម្ពុជាគ្រប់រូប ពិសេសជនក្រីក្រនិងជនងាយរងគ្រោះ នឹងបានទទួលផលប្រយោជន៍ពីសំណាញ់សុវត្ថិភាពសង្គម និងរបបសន្តិសុខសង្គមឱ្យកាន់តែប្រសើរឡើង ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រជាតិគាំពារសង្គមដ៏មានប្រសិទ្ធភាព សមស្រប ដែលអាចអនុវត្ត និងមាននិរន្តរភាព"** ។ ក្នុងដំណាក់កាលមធ្យម យ.ជ.គ.ស. មានគោលបំណងឱ្យ **"ជនក្រីក្រនិង ជនងាយរងគ្រោះកម្ពុជា នឹងទទួលការគាំពារកាន់តែប្រសើរឡើងពីភាពក្រីក្ររ៉ាំរ៉ៃ ភាពអត់ឃ្លាន វិបត្តិ ភាពខ្វះខាត និងមូលហេតុសង្គម និងទទួលបានប្រយោជន៍ពីការធ្វើវិនិយោគលើធនធានមូលធនមនុស្សរបស់ពួកគាត់"** ។

ក្នុងក្របខណ្ឌឆ្ពោះទៅកាន់ឆ្នាំគោលដៅ២០១៥ យ.ជ.គ.ស. នឹងផ្សារភ្ជាប់ស្ថានភាពដែលមានស្រាប់នាពេលបច្ចុប្បន្ន ជាមួយនឹងការរៀបចំគោលដៅដែលមានលក្ខណៈចម្រុះនិងជាប្រព័ន្ធ និងឆ្ពោះទៅកាន់ការផ្តល់ជូនដល់ប្រជាជនក្រីក្រនិងងាយរងគ្រោះ នូវការគាំពារឱ្យកាន់តែប្រសើរឡើងពីភាពក្រីក្រ និងការវិនិយោគលើធនធានមនុស្ស។ ដើម្បីសម្រេចបានការផ្សារភ្ជាប់នេះ យ.ជ.គ.ស.បានរៀបចំជំហានមួយចំនួនដូចខាងក្រោម :

- ជំរុញឱ្យមានការបញ្ចូលគ្នានៃកម្មវិធីដែលគ្របដណ្តប់លើភាពក្រីក្ររ៉ាំរ៉ៃ និងភាពក្រីក្រដែលទើបនឹងកើតឡើង ក៏ដូចជាភាពអត់ឃ្លាន ព្រមទាំងជួយលើកកម្ពស់មូលធនមនុស្ស។
- ពង្រឹងការសម្របសម្រួល ការពង្រីក និងការធ្វើសុខដុមនីយកម្មលើអន្តរាគមន៍ដែលមានស្រាប់ដើម្បី ផ្សារភ្ជាប់ប្រភពសំខាន់នៃភាពងាយរងគ្រោះទៅនឹងកម្មវិធីដែលមានស្រាប់។
- វាយតម្លៃដើម្បីធ្វើការកែលម្អក្នុងករណីចាំបាច់ លើយន្តការកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រដែលមានស្រាប់នាពេលបច្ចុប្បន្ន។
- ពង្រីកវិសាលភាពនៃអន្តរាគមន៍មួយចំនួនដែលកំពុងតែដំណើរការ ដើម្បីបង្កើនឥទ្ធិពល និងប្រសិទ្ធភាព។
- អនុវត្តសាកល្បង វាយតម្លៃ និងពង្រីក ដោយផ្អែកលើប្រសិទ្ធភាពនិងនិរន្តរភាពនូវប្រភេទកម្មវិធីថ្មី ដើម្បីបំពេញចន្លោះប្រហោងនៃកិច្ចគាំពារសង្គមដែលមានស្រាប់សម្រាប់ជនក្រីក្រ និងងាយរងគ្រោះ។

### រូបទី២. ដំណើរការជាលំដាប់ឆ្ពោះទៅកាន់ការគាំពារសង្គមដ៏ស៊ីជម្រៅ




## ៤.២ គោលដៅទាំង៥នៃយុទ្ធសាស្ត្រជាតិគាំពារសង្គម

ប្រទេសកម្ពុជាបានអនុវត្តគម្រោងនិងកម្មវិធីបណ្តាញសុវត្ថិភាពសង្គមជាច្រើន ដែលភាគច្រើនជាការផ្តល់ហិរញ្ញប្បទានពីប្រភពខាងក្រៅ នៅក្នុងការធ្វើសមាហរណកម្មនិងការស្តារឡើងវិញ ដើម្បីកែលម្អសន្តិសុខស្បៀង និងជីវភាពជូនប្រជាជនក្រីក្រ និងដើម្បីឆ្លើយតបទៅនឹងស្ថានភាពបន្ទាន់ អស់រយៈពេលជាង២០ឆ្នាំមកហើយ។ ជោគជ័យជាច្រើន ជាពិសេសនៅក្នុងការផ្តល់ជូនអ្នកទទួលផលក្នុងចំនួនដ៏ច្រើន និងក្នុងការបង្កើនលទ្ធភាពទទួលបាននូវសេវាកម្ម ស្បៀងអាហារ និងសន្តិសុខនៃការរកប្រាក់ចំណូលរួមមាន :

- ការចែកចាយស្បៀង ទៅតាមតំបន់អសន្តិសុខស្បៀង ការផ្តល់អាហារនៅសាលារៀន របបស្បៀងយកទៅផ្ទះ និងកម្មវិធីស្បៀងពលកម្ម បានផ្តល់ជាមូលដ្ឋានក្នុងការឆ្លើយតបទៅនឹងអសន្តិសុខស្បៀង ភាពក្រីក្ររ៉ាំរ៉ៃ និងក្នុងករណីខ្លះ បញ្ហាកង្វះអាហារូបត្ថម្ភ។
- អាហារូបករណ៍ បានផ្តល់ជាមូលដ្ឋានដោះស្រាយស្ថានភាពក្រីក្រ ចំពោះកុមារដែលពេញវ័យចូលរៀន។

- កម្មវិធីសំណង់សាធារណៈ បានផ្តល់ជាមូលដ្ឋានដល់ការឆ្លើយតបទៅនឹងបញ្ហាអសន្តិសុខស្បៀង ភាពខ្វះ ការងារ និងភាពក្រីក្ររ៉ាំរ៉ៃ នៃប្រជាជនដែលពេញវ័យការងារ ។
- មូលនិធិសមធម៌សុខភាព និងគម្រោងការធានារ៉ាប់រងសុខភាពនៅសហគមន៍ បានផ្តល់ជាមូលដ្ឋានក្នុងការគាំពារសុខភាពសម្រាប់ជនក្រីក្រ ។
- សេវាកម្មសុខុមាលភាពសង្គមដល់ក្រុមជនងាយរងគ្រោះពិសេស ដូចជាជនពិការ ចាស់ជរា កុមារកំព្រា ... ។ល ។
- កម្មវិធីផ្សេងៗទៀតមួយចំនួនដែលជាប្រពៃណី និងវប្បធម៌នៃការចែករំលែកធនធាន សម្រាប់បុព្វហេតុមនុស្សធម៌ ។

ប៉ុន្តែកម្ពុជាពុំទាន់មានបណ្តាញសុវត្ថិភាពសង្គមដែលមានប្រសិទ្ធភាព និងមានលក្ខណៈចម្រុះនិងជាប្រព័ន្ធនៅឡើយ ។ អន្តរាគមន៍ភាគច្រើននៅមានភាពរាយប៉ាយនិងមានលក្ខណៈបណ្តោះអាសន្ន ហើយមានភាពពឹងផ្អែកខ្លាំងទៅលើហិរញ្ញប្បទានពីស្ថាប័នផ្តល់ជំនួយ និងវិភាគទានជាលក្ខណៈបុគ្គល ។ វិសាលភាពនៃកម្មវិធីគាំពារសង្គមដែលមានស្រាប់សម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះនៅមានកម្រិតបំផុត ហើយសកម្មភាពទាំងនោះពុំបានផ្តោតខ្លាំងទៅលើតំបន់ដែលមានភាពក្រីក្របំផុតទេ នៅក្នុងកិច្ចខិតខំប្រឹងប្រែងដែលមានភាពបែកខ្ញែកពីគ្នា ដោយសារការសម្របសម្រួលរវាងក្រសួងនិងស្ថាប័នដែលចូលរួមពាក់ព័ន្ធនៅមានកម្រិត ។

ក្នុងភាពជាយុទ្ធសាស្ត្របំពេញបន្ថែម ដល់យុទ្ធសាស្ត្រនិងផែនការតាមវិស័យដទៃទៀតនៃក្រសួងស្ថាប័នពាក់ព័ន្ធ ដែលជាប់ទាក់ទងដោយផ្ទាល់ឬដោយប្រយោលទៅនឹងការគាំពារសង្គម យ.ជ.គ.ស មានគោលដៅជាក់លាក់ ដូចខាងក្រោម ៖

- ជនក្រីក្រ និងជនងាយរងគ្រោះ ទទួលបានការគាំទ្រ រួមមានស្បៀង អនាម័យ ទឹក និងជម្រក ។ល ។ ដើម្បីបំពេញតាមតម្រូវការរបស់ពួកគាត់ ក្នុងដំណាក់កាលមានគ្រោះអាសន្ន និងវិបត្តិ ។
- ជនក្រីក្រ កុមារ និងមាតាងាយរងគ្រោះ ទទួលបានផលប្រយោជន៍ពីសំណាញ់សុវត្ថិភាពសង្គម ដើម្បីកាត់បន្ថយភាពក្រីក្រ និងអសន្តិសុខស្បៀង និងពង្រឹងការអភិវឌ្ឍមូលធនមនុស្ស តាមរយៈការបង្កើនគុណភាពអាហារូបត្ថម្ភ សុខភាពមាតា ទារក និងកុមារ ការលើកកម្ពស់ការអប់រំ និងការលុបបំបាត់ពលកម្មកុមារ ជាពិសេសទម្រង់ធ្ងន់ធ្ងរ ។

- ជនក្រីក្រ និងជនងាយរងគ្រោះដែលពេញវ័យធ្វើការងារ ទទួលបានផលប្រយោជន៍ពីកាលានុវត្តភាពការងារ ដើម្បីធានាឱ្យមានប្រាក់ចំណូល ស្បៀង និងមានការងារធ្វើ ព្រមទាំងចូលរួមក្នុងការកសាងធនធានរូបវន្ត និងធនធានហេដ្ឋារចនាសម្ព័ន្ធសង្គម ប្រកបដោយនិរន្តរភាព ។
- ជនក្រីក្រ និងជនងាយរងគ្រោះ ទទួលបានដោយមានប្រសិទ្ធភាព នូវការថែរក្សាសុខភាពដែលមានគុណភាព និងដែលអាចទទួលប្រើបាន និងការគាំពារផ្នែកហិរញ្ញវត្ថុ ពេលមានជំងឺ ។
- ក្រុមជនងាយរងគ្រោះពិសេស រួមមានក្មេងកំព្រា ចាស់ជរា ស្ត្រីជាមេគ្រួសារ ជនពិការ ជនផ្ទុកមេរោគអេដស៍ ឬអ្នកជំងឺរបេង ។ល។ ទទួលបានការគាំទ្រជាប្រាក់ចំណូល សម្ភារៈ និងចិត្តសាស្ត្រសង្គម ព្រមទាំងការថែទាំសង្គមគ្រប់គ្រាន់ ។

## តារាងទី២. គោលដៅរបស់ យ.ជ.គ.ស. និងការផ្សារភ្ជាប់ជាមួយគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា[៦]

| វិស័យអាទិភាព និងការផ្សារភ្ជាប់នឹងនៅ គ.អ.ស.ក. | គោលដៅ | ជម្រើសកម្មវិធី ឬឧបករណ៍សម្រាប់រយៈពេលមធ្យម |
|---|---|---|
| ឆ្លើយតបនូវតម្រូវការជាមូលដ្ឋានរបស់ជនក្រីក្រ និងជនងាយរងគ្រោះ ក្នុងស្ថានភាពរងគ្រោះអាសន្ន និងកលិយុគ (គ.អ.ស.ក. ១, ៩) | *ជនក្រីក្រ និងជនងាយរងគ្រោះ ទទួលបានការគាំទ្រ ដែលរួមមានស្បៀង អនាម័យ ទឹក និងជម្រក ... ដើម្បីបំពេញតាមតម្រូវការរបស់ពួកគាត់ ក្នុងដំណាក់កាលមានគ្រោះអាសន្ន និងវិបត្តិ* | - ការចែកចាយស្បៀងដោយមានគោលដៅ<br>- ការចែកចាយទុន សម្ភារៈកសិកម្ម និងប្រតិបត្តិការជំនួយក្នុងគ្រោះអាសន្នដទៃទៀត |
| កាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះនៃកុមារ និងមាតា និងបង្កើនការអភិវឌ្ឍធនធាន មនុស្សសម្រាប់ពួកគាត់ (គ.អ.ស.ក. ១, ២, ៣, ៤, ៥) | *ជនក្រីក្រ កុមារ និងមាតាងាយរងគ្រោះ ទទួលបានផលប្រយោជន៍ពីសំណាញ់សុវត្ថិភាពសង្គម ដើម្បីកាត់បន្ថយភាពក្រីក្រនិងអសន្តិសុខស្បៀង និងពង្រឹងការអភិវឌ្ឍមូលធនមនុស្ស តាមរយៈ ការបង្កើនគុណភាពអាហារូបត្ថម្ភ សុខភាពមាតា និងកុមារ ការលើកកម្ពស់ការអប់រំ និងការលុបបំបាត់ពលកម្មកុមារ ជាពិសេសទម្រង់ធ្ងន់ធ្ងរ* | - ការឧបត្ថម្ភសាច់ប្រាក់ ស្បៀង ឬសម្ភារៈដទៃទៀត សម្រាប់កុមារនិងស្ត្រី (រួមមានការឧបត្ថម្ភសាច់ប្រាក់ ដែលផ្តោតលើអាហារូបត្ថម្ភមាតា និងកុមារ ការឧបត្ថម្ភសាច់ប្រាក់ដែលលើកកម្ពស់ការអប់រំ និងកាត់បន្ថយពលកម្មកុមារ ការផ្តល់អាហារមានជីវជាតិបន្ថែមដល់ស្ត្រី មានផ្ទៃពោះ ម្តាយបំបៅដោះកូន និងកុមារ) |

---

៦ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាមាន៩ រួមមាន ការលុបបំបាត់ភាពក្រីក្រនិងភាពអត់ឃ្លាន ការសម្រេចឱ្យបានការអប់រំមូលដ្ឋានសម្រាប់គ្រប់ៗគ្នា បង្កើនសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី ការកាត់បន្ថយមរណភាពកុមារ ការបង្កើនសុខភាពមាតា ការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍ គ្រុនចាញ់ និងជំងឺផ្សេងៗទៀត ការធានានិរន្តរភាពបរិស្ថាន ការរៀបចំបង្កើតភាពជាដៃគូសកលសម្រាប់ការអភិវឌ្ឍ និង ការបោសសំអាតមីន យុទ្ធភណ្ឌមិនទាន់ផ្ទុះ និងការទ្រទ្រង់ដល់ជនរងគ្រោះ ។

| វិស័យអាទិភាព និងការផ្សារភ្ជាប់នឹងទៅ គ.អ.ស.ក. | គោលដៅ | ជម្រើសកម្មវិធី ឬឧបករណ៍សម្រាប់រយៈពេលមធ្យម |
|---|---|---|
| | | - ការផ្តល់អាហារនៅសាលារៀន របបស្បៀងយកទៅផ្ទះ<br>- សេវាកម្មផ្សព្វផ្សាយ និង កម្មវិធីឱកាសថ្មីសម្រាប់យុវជននៅក្រៅសាលារៀន និងការគាំទ្រដល់សេវាកម្មសុខុមាលភាពសង្គម |
| ឆ្លើយតបនូវភាពខ្វះការងារ និងភាពគ្មានការងារដែលកើតមានឡើងតាមរដូវកាល និងផ្តល់ឱកាស សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគាត់ (គ.អ.ស.ក. ១) | *ជនក្រីក្រ និងជនងាយរងគ្រោះដែលពេញវ័យធ្វើការងារ ទទួលបានផលប្រយោជន៍ពីកាលានុវត្តភាព ការងារ ដើម្បីធានាឱ្យមានប្រាក់ចំណូលស្បៀង និងមានការងារធ្វើ ព្រមទាំងចូលរួមក្នុងការកសាងធនធានរូបវន្ត និងធនធានហេដ្ឋារចនាសម្ព័ន្ធសង្គមប្រកបដោយនិរន្តរភាព* | - កម្មវិធីសំណង់សាធារណៈអតិពលកម្មជាតិ<br>- គម្រោងស្បៀងពលកម្ម និងសាច់ប្រាក់ពលកម្ម |
| បង្កើនការថែទាំសុខភាពដែលអាចទទួលយកបាន ដល់ជនក្រីក្រ និងជនងាយរងគ្រោះ (គ.អ.ស.ក. ៤, ៥, ៦) | *ជនក្រីក្រ និងជនងាយរងគ្រោះ ទទួលបានដោយមានប្រសិទ្ធភាព នូវការថែរក្សាសុខភាពដែលមានគុណភាព និងដែលអាចទទួលប្រើបាន និងការគាំពារផ្នែកហិរញ្ញវត្ថុ ពេលមានជំងឺ* | - ការពង្រីកមូលនិធិសមធម៌សុខភាព (សម្រាប់ជនក្រីក្រ) និងការធានារ៉ាប់រងសុខភាពនៅសហគមន៍ (សម្រាប់ប្រជាជនស្ថិតនៅក្បែរបន្ទាត់នៃភាពក្រីក្រ) ដូចមានចែងក្នុងផែនការមេស្តីពីការគាំពារសុខភាពសង្គម (នៅរង់ចាំការអនុម័ត) |
| បង្កើនការគាំពារសង្គមសម្រាប់ជនងាយរងគ្រោះពិសេសមួយចំនួន (គ.អ.ស.ក. ១, ៦, ៩) | *ក្រុមជនងាយរងគ្រោះពិសេស រួមមានក្មេងកំព្រា ចាស់ជរា ស្ត្រីជាមេគ្រួសារ ជនពិការ ជនផ្ទុកមេរោគអេដស៍ ឬអ្នកជំងឺរបេង ។ល។ ទទួលបានការគាំទ្រជាប្រាក់ចំណូល សម្ភារៈ និងចិត្តសាស្ត្រសង្គម ព្រមទាំងការថែទាំសង្គមគ្រប់គ្រាន់* | - សេវាកម្មសុខុមាលភាពសង្គមសម្រាប់ក្រុមជនងាយរងគ្រោះពិសេស<br>- ការឧបត្ថម្ភសង្គម និងប្រាក់សោធននិវត្តន៍សង្គមសម្រាប់មនុស្សចាស់ និងអ្នកដែលមានជំងឺរ៉ាំរ៉ៃ ឬជនពិការ |

គ.អ.ស.ក. : គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា

## ៤.៣ ការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម

**ការអនុវត្តយុទ្ធសាស្ត្រនេះ នឹងទាមទារឱ្យពង្រីកបន្ថែមនូវអន្តរាគមន៍ដែលមានស្រាប់ ការរៀបចំស្ថាប័ន និងការបង្កើតកម្មវិធីថ្មីដើម្បីគ្រប់ដណ្តប់លើចន្លោះប្រហោងដែលមានស្រាប់**។ ដោយសារកម្មវិធីភាគច្រើនក្នុងការគាំពារសង្គមមានលក្ខណៈអន្តរវិស័យ ប្រការនេះទាមទារឱ្យមានការសម្របសម្រួលរវាងក្រសួងស្ថាប័នពាក់ព័ន្ធ ក៏ដូចជាទំនាក់ទំនងយ៉ាងសកម្មជាមួយបណ្តាដៃគូ អភិវឌ្ឍនិងអង្គការសង្គមស៊ីវិលដែលគាំទ្រលើវិស័យនេះ ដើម្បីជៀសវាងការត្រួតជាន់គ្នាជាលក្ខណៈវិស័យការងារ ឬតំបន់ភូមិសាស្ត្រ ក៏ដូចជាដើម្បីធ្វើសុខដុមនីយកម្មលើនីតិវិធីក្នុងការអនុវត្ត និងការសម្របសម្រួលលើការប្រើប្រាស់ធនធានថវិកា។

ជំហានបន្ទាប់ក្នុងការរៀបចំសម្រាប់ការអនុវត្តយុទ្ធសាស្ត្រនេះ គឺការកំណត់ឱ្យឃើញ និងឱ្យបានច្បាស់លាស់ នូវសកម្មភាពដែលនឹងត្រូវអនុវត្តក្នុងដំណាក់កាលខ្លី ដើម្បីរក្សាស្ថេរភាពនៃវឌ្ឍនភាពការងារដែលសម្រេចបានក្នុងមួយឆ្នាំកន្លងមកលើអណត្តិការងារការគាំពារសង្គម។ ក្នុងដំណាក់កាលខ្លីនិងមធ្យម យ.ជ.គ.ស នឹងផ្តល់អាទិភាពលើការរៀបចំបង្កើតសំណាញ់សុវត្ថិភាពសង្គម ដែលមានប្រសិទ្ធភាពនិងនិរន្តរភាព ដែលផ្តោតគោលដៅលើជនក្រីក្រនិងជនងាយរងគ្រោះ ជាមួយនិងសេវាកម្មសុខុមាលភាពសង្គមបំពេញបន្ថែមសម្រាប់ក្រុមជនងាយរងគ្រោះពិសេស។ ក្នុងដំណាក់កាលវែង យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ បានកំណត់ក្របខណ្ឌការគាំពារសង្គមដែលមាននិរន្តរភាពនិងស៊ីជម្រៅសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប ដោយសម្រេចបាននូវវិសាលភាពគ្របដណ្តប់សកលលើហានិភ័យ និងភាពងាយរងគ្រោះ ជាមួយនឹងកញ្ចប់ជំនួយឧបត្ថម្ភនិងសេវាកម្មមូលដ្ឋាន ដែលមានលក្ខណៈសមរម្យទៅតាមការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ប្រការនេះរួមមានទាំងយន្តការរបបសន្តិសុខសង្គមដោយមានភាគទានសម្រាប់វិស័យផ្លូវការ និងការធ្វើឱ្យកាន់តែប្រសើរឡើងនូវសំណាញ់សុវត្ថិភាពសង្គមសម្រាប់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ (រាជរដ្ឋាភិបាលកម្ពុជា, ២០១១)។

## ៥. ទស្សនាទានរនៃ "សមធម៌សង្គម"

**"សមធម៌សង្គម"** គឺជាស្នូលកណ្តាលនៃការអភិវឌ្ឍប្រកបដោយចីរភាព។ ទស្សនាទានដំបូងស្តីពីសមធម៌ គឺថាមនុស្សគ្រប់រូបគួរទទួលបានលាភការទៅតាមអ្វីៗដែលពួកគាត់បានផ្តល់ទៅកាន់សង្គម។ ពាក្យ **"សមធម៌"** សង្កត់ធ្ងន់ទៅលើគោលការណ៍នៃភាពឥតល្អៀង និងយុត្តិធម៌សង្គម។ ភាពខុសគ្នារវាងក្រុមប្រជាជន ដែលកើតឡើងដោយពុំបណ្តាលមកពីលក្ខខណ្ឌជីវសាស្ត្រ ហើយដែលអាចជៀសវាងបាន គឺជា

"**អសមធម៌**" ។ ប៉ុន្តែបើភាពខុសគ្នារវាងក្រុមប្រជាជន កើតឡើងដោយសារបណ្តាលមកពីយេនឌ័រ ភេទ និងអាយុ គឺជា "**វិសមភាព**" ។ ភាពខុសៗគ្នានៃលទ្ធភាព និងជម្រើសរបស់មនុស្សម្នាក់ៗ នឹងនាំទៅរកភាពខុសគ្នានៃលទ្ធផល ទោះបីស្ថិតក្នុងកាលានុវត្តភាពដូចគ្នា និងការទទួលបានធនធានដូចគ្នាក៏ដោយ។ កម្រិតដាច់ខាតនៃភាពខុសគ្នានេះក៏ជាចំនុចគួរឱ្យកត់សម្គាល់ ព្រោះថាជនក្រីក្រនិងជនងាយរងគ្រោះបំផុត (រួមទាំងជនពិការ ជនចាស់ជរាក្រីក្រ ស្ត្រីមេម៉ាយ កុមារក្រីក្រ ...) មានសេចក្តីត្រូវការសេវាសាធារណៈខ្ពស់ដើម្បីសម្រេចបាននូវកម្រិតលទ្ធភាពដូចជនដទៃ។ ទោះបីជា **អសមធម៌** និង **វិសមភាព** មានទស្សនាទានខុសគ្នាក៏ដោយ ក៏លទ្ធផលដែលកើតចេញពីបញ្ហាទាំងពីរនេះមានទំនាក់ទំនងគ្នាយ៉ាងជាក់លាក់ ពីព្រោះវិសមភាពនៃលទ្ធផល (ជីវភាពរស់នៅ សុខភាព ការសិក្សាអប់រំ...) គឺជាផលិតផលនៃអសមធម៌នៃការទទួលបាន សេវាសាធារណៈ និងអសមធម៌នៃសមត្ថភាព។

**សមធម៌** មិនមែនមានន័យថាប្រជាពលរដ្ឋគ្រប់រូបត្រូវរង់ចាំតែទទួលផលប្រយោជន៍ពីការអភិវឌ្ឍស្មើៗគ្នា ទោះបីមានលទ្ធភាព សមត្ថភាព តួនាទី ភារកិច្ច និងការទទួលខុសត្រូវខុសៗគ្នា ឬមិនបានចូលរួមចំណែកក្នុងការងារបង្កបង្កើនផលនោះទេ។ ប៉ុន្តែវាអាស្រ័យលើឱកាស ការខិតខំប្រឹងប្រែង លទ្ធភាពនិងសមត្ថភាព និងធនធានរបស់បុគ្គលម្នាក់ៗ ដើម្បីទាញយកប្រយោជន៍ដែលខ្លួនអាច ទទួលយកបានក្នុងក្របខណ្ឌនៃច្បាប់។

**សមធម៌**[7] ក្នុងន័យនេះ គឺការផ្តល់កាលានុវត្តភាពជូនដល់ពលរដ្ឋគ្រប់រូប ទាំងស្រី ទាំងប្រុស ទាំងចាស់ ទាំងក្មេង មានឱកាសចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គមជាតិនិងគ្រួសារ បានដោយសេរី

---

[7]

Equity - Fairness and impartiality towards all concerned, based on the principles of evenhanded dealing. Equity implies giving as much advantage, consideration, or latitude to one party as it is given to another. Along with economy, effectiveness, and efficiency, Equity is essential for ensuring that extent and costs of funds, goods and services are fairly divided among their recipients.
Social Inequality - is characterized by the existence of unequal opportunities and rewards for different social positions or statuses within a group or society. It contains structured and recurrent patterns of unequal distributions of goods, wealth, opportunities, rewards, and punishments.
There are two main ways to measure social inequality: inequality of conditions, and inequality of opportunities. Inequality of conditions refers to the unequal distribution of income, wealth and material goods. Housing, for example, is an inequality of conditions with the homeless and those living in housing projects sitting at the bottom of the hierarchy while those living in multi-million dollar mansions sitting at the top.
Inequality of opportunities refers to the unequal distribution of "life chances" across individuals. This is reflected in measures such as level of education, health status, and treatment by the criminal justice system. For example, why do upper-class white males typically have more opportunities for wealth and success compared to lower-class black males, who have a higher chance of landing in the criminal justice system?

ត្រឹមត្រូវ យុត្តិធម៌ តាមសមត្ថភាព និងលទ្ធភាពរៀងៗខ្លួន។ ក្នុងហេតុផលនេះ ការធ្វើកំណែទម្រង់គឺមិនមែនដើម្បីជំរុញកំណើនសេដ្ឋកិច្ចតែមួយជ្រុងទេ គឺជាការប្រមាណនូវការប្រើប្រាស់ធនធានសរុប មានធនធានមនុស្ស ធនធានធម្មជាតិ ជាដើម ដែលបានទទួលការបណ្តុះបណ្តាល ពង្រឹង កែច្នៃ ឱ្យបានស័ក្តសិទ្ធ សមស្រប ដើម្បីធានាការអភិវឌ្ឍន៍ឱ្យមានប្រសិទ្ធភាព សមធម៌ និងរក្សាបាននូវចិរភាពយូរអង្វែងផងដែរ ។

នៅពេលខ្លះ ការពិភាក្សាលើសមធម៌កើតចេញមកពីទស្សនាទាននៃ **សមភាពសីលធម៌** ដែលកំណត់ថាមនុស្សគ្រប់រូបត្រូវទទួលបានអ្វីៗឱ្យដូចគ្នា។ ការសង្កត់ធ្ងន់ទៅលើសមធម៌ អាចជួយឱ្យអ្នកនយោបាយ និងអ្នកអនុវត្តយុទ្ធសាស្ត្រ អាចធ្វើការសម្រេចចិត្តលើបែបផែននិងនីតិវិធីនៃការបែងចែកសេវាសាធារណៈនៅក្នុងសង្គម តាមរយៈការទទួលខុសត្រូវរបស់រដ្ឋទៅលើការផ្តល់សេវាកម្មទាំងនេះ និងដើម្បីធានាថាសេវាទាំងនេះត្រូវបានបែងចែកដោយសមធម៌ **(Jone, 2009)** ។

នៅក្នុងអត្ថន័យសេដ្ឋកិច្ច **សមធម៌សេដ្ឋកិច្ច** គឺជាភាពស្មើគ្នានៅក្នុងវិស័យសេដ្ឋកិច្ច ពិសេសក្នុងបរិបទនៃការធ្វើវិភាគទាន ការបង់ពន្ធ និងការទទួលបានសុខមាលភាពសេដ្ឋកិច្ច។ ក្នុងន័យនេះ **សមធម៌សេដ្ឋកិច្ច** សំដៅលើឱកាសស្មើគ្នានៃមនុស្សម្នាក់ៗ ដោយពុំអាស្រ័យលើអត្តសញ្ញាណ ក្នុងការទទួលបានក្នុងកម្រិតអប្បបរមាជាមូលដ្ឋាននៃសេវាសាធារណៈ និងប្រាក់ចំណូលឱ្យបានដូចគ្នា **(Bird, 2009)** ។

**សមធម៌នៃការសិក្សាអប់រំ** អាចបកស្រាយបានក្នុងអត្ថន័យពីរយ៉ាង។ ទីមួយ សមធម៌នៃការសិក្សាអប់រំ គឺជាបញ្ហាដែលទាក់ទងនឹងភាពស្មើគ្នានៃប្រជាជនម្នាក់ៗ ក្នុងការសម្រេចបានលទ្ធផលនៃការសិក្សាអប់រំ ដោយផ្អែកលើលទ្ធភាព និងការប៉ងប្រាថ្នា ហើយដោយពុំអាស្រ័យលើកត្តាផ្សេងៗ រួមមានយេនឌ័រ ស្ថានភាពសេដ្ឋកិច្ចសង្គម ឬជាតិសាសន៍ឡើយ។ ទីពីរ គឺប្រជាជនម្នាក់ៗ ត្រូវមានសិទ្ធិទទួលបានការសិក្សាអប់រំក្នុងកម្រិតមូលដ្ឋានមួយឱ្យបានដូចគ្នា។

**សមធម៌សុខាភិបាល** ផ្តោតការយកចិត្តទុកដាក់លើភាពខុសគ្នានៃគុណភាពផ្នែកសុខភាព និងគុណភាពនៃសេវាសុខាភិបាល ដែលផ្តល់ជូនដល់ប្រជាជនទាំងអស់ ហើយការវិភាគទាំងនេះសង្កត់ធ្ងន់លើការកកើតនិងរាលដាលនៃជំងឺ លទ្ធផលផ្នែកសុខភាព ឬការទទួលបានការថែទាំសុខភាព **(Goldberg et al.,**

**2004)** ដែលអាចនឹងមានភាពខុសគ្នាទៅតាមជាតិសាសន៍ ភេទ និងស្ថានភាពសេដ្ឋកិច្ចសង្គម។ សមធម៌សុខាភិបាល អាចចែកចេញជាពីរផ្នែក គឺ

- សមធម៌សុខាភិបាលជាលក្ខណៈជួរដេក : គឺការទទួលបានការថែទាំ និងព្យាបាលដូចគ្នា សម្រាប់គ្រប់ក្រុមប្រជាជនទាំងអស់ នៅក្នុងកាលៈទេសៈដូចគ្នា
- សមធម៌សុខាភិបាលជាលក្ខណៈជួរឈរ : គឺផ្អែកលើគោលការណ៍ដែលថាក្រុមប្រជាជនដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមពុំស្មើក្រុមដទៃ គួរទទួលបាលការថែទាំនិងព្យាបាល ទៅតាមកម្រិតនៃតម្រូវការមួយជាក់លាក់

**អសមធម៌** គឺជាបញ្ហាដែលត្រូវទទួលការយកចិត្តទុកដាក់ ជាពិសេសនៅក្នុងបរិបទនៃប្រទេសកំពុងអភិវឌ្ឍ។ ការទទួលបាន និងទំនាក់ទំនងរបស់ប្រជាជនចំពោះសេវាសាធារណៈ ត្រូវបានកំណត់ទ្រង់ទ្រាយដោយស្ថានភាពសេដ្ឋកិច្ចសង្គម ហើយដែលអាចនាំទៅរកកង្វះការប្រាស្រ័យទាក់ទង និងភាពឯកោនៅក្នុងសង្គម។ **អសមធម៌នៃប្រាក់ចំណូល** ក្នុងករណីនេះ អាចកើតឡើងបន្តពីមួយជំនាន់ទៅមួយជំនាន់ និងពីតំបន់មួយទៅតំបន់មួយ ក្នុងប្រទេសតែមួយ។ ដូចដែលបានរៀបរាប់ខាងលើ អសមធម៌លើផ្នែកសិក្សាអប់រំ សុខាភិបាល និងប្រាក់ចំណូល រវាងប្រជាជន នឹងមានឥទ្ធិពលយ៉ាងអវិជ្ជមានចំពោះកំណើន ការកាត់បន្ថយភាពក្រីក្រ និងសុខុដុមរមនាសង្គម។

## ៥. ស្ថានភាពនៃភាពក្រីក្រ និងក្រុមជនងាយរងគ្រោះ

យោងតាមការសន្និដ្ឋានរបស់ **ក្រុមប្រឹក្សាអន្តរជាតិដើម្បីសុខុមាលភាពសង្គម** ដែលមានបទពិសោធន៍រយៈពេលជាង៨៥ឆ្នាំ នៅក្នុងប្រទេសជាង៧០ លើពិភពលោក (តាំងពីឆ្នាំ១៩២៨) បានលើកឡើងថា **"គ្មានប្រទេសណាមួយអាចឆ្លងផុតចេញពីអន្ទាក់នៃប្រទេសមានប្រាក់ចំណូលមធ្យមបានទេ (Middle Income Traps) បើសិនជាវិសមភាពក្នុងប្រទេសនោះមានកម្រិតខ្ពស់"**។ កំណើនសេដ្ឋកិច្ច គឺជាកត្តាចាំបាច់ដើម្បីកាត់បន្ថយភាពក្រីក្រ ប៉ុន្តែក៏មិនប្រាកដថាជាលក្ខខណ្ឌតែមួយគត់នោះដែរ[8]។ មតិខ្លះបានលើកជាទស្សនទានថា កំណើនសេដ្ឋកិច្ច នឹងមានឥទ្ធិពលបែងចែកជាបន្តដល់ប្រជាពលរដ្ឋគ្រប់រូប ជាពិសេសក្រុមជនក្រីក្រ **(Trickle-down**

---

[8] **International Council on Social Welfare**, A world Organization Promoting Social Development : Letter to The Executive Directors of the World Bank, New York and Entebbe, 12 April 2013. *"No country has successfully transited beyond middle-income status with high levels of inequality". ... Our organization has observed over its 85 years history, that economic growth is a facilitating factor for the reduction of poverty but is by no means a sufficient condition.*

**concept of economic and social development)**។ ប៉ុន្តែយោងតាមសិក្សារបស់ធនាគារពិភពលោក (២០០៩) បង្ហាញថានៅចន្លោះឆ្នាំ២០០៤-២០០៧ ប្រាក់ចំណូលជាមធ្យមរបស់ប្រជាពលរដ្ឋកម្ពុជាម្នាក់ៗ កើន ៧.៥%ក្នុង១ឆ្នាំ ប៉ុន្តែការប្រើប្រាស់ប្រចាំឆ្នាំ **(annual consumption)** របស់ក្រុមអ្នកក្រ ស្ថិតនៅបញ្ចូ **ភាគទី១និងទី២** (៤០%ក្រោម) បានកើនតែ ២.៦%ប៉ុណ្ណោះ។ ដោយឡែក ការប្រើប្រាស់ប្រចាំឆ្នាំរបស់ក្រុមអ្នកមាននៅបញ្ចូភាគទី៥ (២០%លើ) មានកំណើនឡើងដល់៦.៧% **(CDRI, 2012)** បានន័យថា កាលានុវត្តភាព និងផ្លែផ្កានៃកំណើនសេដ្ឋកិច្ច នៅមិនទាន់អាចធានាបែងចែកប្រកបដោយសមធម៌នៅឡើយនៅកម្ពុជា។ ដូច្នេះហើយបានជា ក្នុងរបៀបវារៈនៃការអភិវឌ្ឍន៍សម័យក្រោយឆ្នាំ២០១៥ ទាមទារឱ្យមេដឹកនាំជាន់ខ្ពស់កម្រិតជាតិនិងកម្រិតពិភពលោក រួមគ្នាពិភាក្សាពិចារណាសារឡើងពីទស្សនទាននិងរបៀបវារៈនៃការអភិវឌ្ឍដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

ទារកនិងកុមារ ព្រមទាំងនារីនិងស្ត្រីដែលស្ថិតនៅក្នុងវ័យបន្តពូជ និងជាពិសេសគ្រួសារដែលជួបប្រទះអសន្តិសុខស្បៀងមានភាពងាយរងគ្រោះខ្ពស់ ដូច្នេះហើយពួកគាត់គួរតែជាគោលដៅនៃអន្តរាគមន៍គាំពារសង្គម។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះស្ថានភាពមរណភាពកុមារមានសភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ដោយបានថយចុះពី៩៥មកត្រឹម៦០នាក់ក្នុងទារក១០០០នាក់ ពីឆ្នាំ២០០០ដល់២០០៨ (ជាការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្ស) ហើយអត្រាមរណរបស់កុមារក្រោមអាយុ៥ឆ្នាំ បានថយចុះពី១២៤មកត្រឹម៨៣នាក់ ក្នុងកំណើតទារក១០០០នាក់ (ស្ទើរតែសម្រេចបានគោលដៅអភិវឌ្ឍនិសហស្សវត្សរ៍ដែលកំណត់យក៧៥នាក់)។ ប៉ុន្តែភាពខុសគ្នាតាមតំបន់នៅមានកម្រិតខ្ពស់ ព្រោះមរណភាពទារក និងកុមារអាយុក្រោម៥ឆ្នាំ នៅតែមានចំនួនស្ទើរតែ២ដងនៃអត្រាមធ្យមភាគជាតិក្នុង ខេត្តកំពង់ស្ពឺ ព្រះវិហារ ស្ទឹងត្រែង ព្រៃវែង មណ្ឌលគិរី និង រតនគិរី ដែលនេះជាបញ្ហាដែលត្រូវដោះស្រាយ (ក្រសួងផែនការឆ្នាំ២០១០)។

ភាពក្រីក្រអាចបង្កឱ្យមានឧបសគ្គដល់លទ្ធភាពបញ្ចប់ការសិក្សាឱ្យបានពេញលេញ។ ការចំណាយដោយប្រយោលមួយចំនួនបានបន្ថែមបន្ទុកលើឪពុកម្តាយកុមារ រួមមានការចំណាយលើឯកសណ្ឋានសម្ភារៈសិក្សា ចំណី អាហារនៅសាលារៀន ការធ្វើដំណើរ និងថ្លៃសាលារៀនក្រៅផ្លូវការ រួមទាំងតម្រូវការរបស់ឪពុកម្តាយក្នុងការធ្វើចំណាកស្រុកស្វែងរកការងារ និងការទទួលស្គាល់តម្លៃឱកាសក្នុងការឱ្យកុមារចូលរៀននៅសាលារៀន ធៀបជាមួយនឹងការមិនចូលរៀនដើម្បីជួយរកប្រាក់សម្រាប់គ្រួសារ។

រូបទី៣. ភាពខុសគ្នានៃលទ្ធផលនៃការសិក្សា (អត្រាបញ្ចប់ការសិក្សាថ្នាក់បឋមសិក្សា) ទៅតាមស្រុកនីមួយៗ




ឆ្នាំសិក្សា២០០៩-២០១០




ឆ្នាំសិក្សា២០១០-២០១១

ប្រភព : EMIS (2011)

ទារកនិងកុមារអាចប្រឈមនឹងហានិភ័យ ដោយសារយុទ្ធសាស្ត្រដោះស្រាយនឹងវិបត្តិដែលមានលក្ខណៈអវិជ្ជមាន ហើយអាចបង្កឱ្យមានផលប៉ះពាល់ដល់កុមារអស់មួយជីវិត ដូចជាការទទួលបានចំណីអាហារដែលមានជីវជាតិបំប៉នតិចតួចឬមិនល្អ ការមិនបានទៅសាលារៀន ការចូលរួមធ្វើការដោយប្រើកម្លាំងពលកម្មកុមារ និងការក្លាយជាជនរងគ្រោះនៃការជួញដូរមនុស្ស។ ទារកនិងកុមារជាជនងាយរងគ្រោះបំផុតពីសំណាក់វិបត្តិនានា ពីព្រោះពួកគាត់ខ្វះសមត្ថភាពកាត់បន្ថយហានិភ័យ និងគ្រប់គ្រងស្ថានភាពមិនបានល្អ។ យោងតាមការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០០៥ កុមារចំនួន៦៤% នៅកម្ពុជា

ប្រឈមនឹងកង្វះខាតសុខុមាលភាពយ៉ាងហោចណាស់លើ បញ្ហា២ ក្នុងចំណោមបញ្ហាចំនួន៧ រួមមាន អាហារ សុខភាព ការអប់រំ ព័ត៌មាន ទឹក អនាម័យ និងជម្រក។

រូបទី៤. ភាពខុសគ្នានៃអត្រាពលកម្មកុមារ (ទិន្នន័យអង្កេតសង្គម-សេដ្ឋកិច្ចកម្ពុជា) នៅតាមតំបន់




## ៦. ការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គមដើម្បីលើកកម្ពស់សមធម៌

ក្រុមការងារជាន់ខ្ពស់ដែលបានចាត់តាំងដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ បានមូលមតិលើក្របខណ្ឌការងារ ដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ផង នឹងរៀបចំឱ្យបាននូវទស្សនទានថ្មីនៃការអភិវឌ្ឍន៍ ដោយធ្វើសមាហរណកម្មនៃការងារជម្រុញកំណើនសេដ្ឋកិច្ច ជាមួយនឹងការងារធានាឱ្យមានសមធម៌សង្គម និងការការពារបរិស្ថាន។ កំណើនសេដ្ឋកិច្ចតែមួយគត់ មិនអាចធានាបាននូវយុត្តិធម៌សង្គម សមភាព និងសុខុមាលភាពយូរអង្វែងរបស់ប្រជាពលរដ្ឋទាំងអស់បានទេ។ សហគមន៍ពិភពលោក ត្រូវតែមានវិធានការជាក់ស្តែងដើម្បីលើកកម្ពស់ការប្រែប្រួលសេដ្ឋកិច្ច-សង្គម ប្រកបដោយចីរភាព និងកំណើនសេដ្ឋកិច្ច ដោយសមធម៌ទាំងនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់ពិភពលោក។

ចំនុចផ្សារភ្ជាប់គ្នារវាង **ការគាំពារសង្គម** និង **សមធម៌** គឺស្ថិតនៅត្រង់ថា ការគាំពារសង្គមគឺជាការឧបត្ថម្ភដែលផ្តល់ទៅដល់ប្រជាជន ដើម្បីឆ្លើយតបទៅនឹងបញ្ហាជាឫសគល់នៃភាពក្រីក្រនិងភាពងាយរងគ្រោះ ព្រមទាំងដើម្បីបង្កើនការអភិវឌ្ឍមូលធនមនុស្សក្នុងពេលជាមួយគ្នា។ ដូច្នេះ ការផ្តល់ការគាំពារសង្គម

ទៅដល់ប្រជាជនគ្រប់រូប និងដោយផ្តោតការយកចិត្តទុកដាក់ទៅលើជនក្រីក្រនិងជនងាយរងគ្រោះ គឺជាមធ្យោបាយប្រកបដោយសមធម៌មួយ ដែលមានចរិកលក្ខណៈជាការទទួលខុសត្រូវរបស់រដ្ឋផង (ពិសេសកម្មវិធីសំណាញ់សុវត្ថិភាពសង្គម) ដើម្បីផ្តល់ជូននិងឆ្លើយតបដល់តម្រូវការជាមូលដ្ឋានរបស់ប្រជាជនគ្រប់រូប និងបង្កើនការចូលរួមដោយស្មើភាពពីប្រជាជនផង (របបសន្តិសុខសង្គម)។ ការគាំពារសង្គម លើកកម្ពស់សមធម៌រវាងប្រជាជននៅក្នុងសង្គម តាមរយៈការកាត់បន្ថយភាពនៅឯកោរបស់ជនក្រីក្រពីការអភិវឌ្ឍន៍ និងការបង្កើនសមភាពនៃកាលានុវត្តភាព។ កម្មវិធីគាំពារសង្គម (មូលនិធិសមធម៌ សុខាភិបាល កម្មវិធីផ្តល់អាហារនៅសាលារៀន កម្មវិធីសំណង់សាធារណៈ កម្មវិធីសង្គហទានសង្គម ការផ្តល់ជំនួយស្បៀង...) ចូលរួមដល់ការកាត់បន្ថយភាពក្រីក្រ និងទុក្ខលំបាករបស់ប្រជាជនក្រីក្រក្នុងអំឡុងពេលមានវិបត្តិ ព្រមទាំងលើកកម្ពស់ការអភិវឌ្ឍមូលធនមនុស្ស (អាហារូបត្ថម្ភ សុខភាព និងការអប់រំ) ដែលដូច្នេះបានសេចក្តីថាការគាំពារសង្គម ចូលរួមចំណែកដល់សមភាពនៃកាលានុវត្តភាព។

### ប្រអប់ទី៦. បទពិសោធន៍នៃកម្មវិធីគាំពារសង្គម Oportunidades នៅប្រទេសម៉ិចស៊ិក

*កម្មវិធី **Oportunidadae** (កាលពីមុនហៅថា **Progresa**) ជាកម្មវិធីគាំពារសង្គមមួយនៃរដ្ឋាភិបាលប្រទេសម៉ិចស៊ិក ដែលផ្តល់លាភការជូនប្រជាជនក្រីក្របំផុតនៅតំបន់ជនបទ។ កម្មវិធីគាំពារសង្គមប្រភេទនេះ មានលក្ខណៈជាការធ្វើសង្គហទានសង្គម ក្នុងការជួយឱ្យគ្រួសារក្រីក្រអាចចាកផុតពីភាពក្រីក្រ ព្រមទាំងលើកទឹកចិត្តឱ្យគ្រួសារនីមួយៗធ្វើការវិនិយោគលើការសិក្សាអប់រំ សុខភាព និងអាហារូបត្ថម្ភសម្រាប់កូនចៅ។*

*កម្មវិធីនេះ បានធ្វើឱ្យអត្រានៃការចុះឈ្មោះចូលរៀន ពិសេសសម្រាប់កុមារី មានការកើនឡើង ជាហេតុធ្វើឱ្យប្រាក់កម្រៃពលកម្មនៃពួកគាត់កើនឡើង ៨% នៅពេលចូលធ្វើការ។ អត្រាឧប្បត្តិហេតុនៃជម្ងឺ បានធ្លាក់ចុះ ១២% ហើយចំនួនថ្ងៃនៃទុព្វលភាព បានធ្លាក់ចុះ១៩%។ កម្មវិធីក៏បានធ្វើឱ្យកុមារអាចទទួលទានអាហារដែលមានថាមពលខ្ពស់ជាងមុន និងកាត់បន្ថយអត្រាស្គមស្គាំង។ ស្ត្រី បានពង្រឹងតួនាទីក្នុងគ្រួសារកាន់តែខ្លាំងជាងមុន ក្នុងនាមជាអ្នកគ្រប់គ្រងថវិកាលាភការនៃកម្មវិធី។*

លក្ខណៈពិសេសមួយនៃការរៀបចំបង្កើតយុទ្ធសាស្ត្រជាតិគាំពារសង្គមនៅកម្ពុជា គឺការដាក់មូលដ្ឋានឈរលើកត្តា **"វដ្តជីវិតមនុស្ស"** ដើម្បីផ្តល់អន្តរាគមន៍និងការវិនិយោគ និងដើម្បីគ្របដណ្តប់លើចន្លោះ

ប្រហោងនៃការអនុវត្តដែលមានស្រាប់។ កត្តាវដ្តជីវិតមនុស្ស ទទួលស្គាល់ថាដំណាក់កាលនីមួយៗនៃជីវិតមនុស្ស មានលក្ខណៈពិសេសដាច់ដោយឡែកពីគ្នា ហើយប្រឈមនឹងភាពងាយរងគ្រោះផ្សេងៗគ្នា ប៉ុន្តែដំណាក់កាលមានផ្ទៃពោះ និងកុមារតូច ជាដំណាក់កាលដែលមានភាពប្រឈមនឹងគ្រោះថ្នាក់ខ្ពស់។ ពេលវេលាទាំងនេះ ជាដំណាក់កាលក្នុងជីវិត ដែលមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍផ្នែកកាយសម្បទា អារម្មណ៍ និងបញ្ញាស្មារតីរបស់កុមារ ត្រូវបានចាប់ផ្តើមឡើង។

រូបទី៥. ការវិភាគនិងរៀបចំកម្មវិធីគាំពារសង្គម ដោយផ្អែកមូលដ្ឋានលើទស្សនាទាននៃវដ្តជីវិតមនុស្ស




ប្រភព ៖ រាជរដ្ឋាភិបាលកម្ពុជា (២០១១)

ការធ្វើវិនិយោគលើការគាំពារសង្គមដោយផ្តោតលើស្ត្រីមានផ្ទៃពោះនិងកុមារ ផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចយ៉ាងច្រើន។ ការសិក្សាជាច្រើនទៅលើកម្រិតនៃផលចំណេញនៃផលចំណេញដែលបានពីការវិនិយោគក្នុងការអភិវឌ្ឍកុមារតូច បានបង្ហាញឱ្យឃើញថា **រាល់ការដាក់វិនិយោគមួយឯកតានៃថវិកាផលចំណេញនឹងមានចាប់ពី២ ដល់១៧ឯកតា**។ ប្រសិនបើកុមារបានទទួលការអប់រំនៅមត្តេយ្យសិក្សាចំនួនមួយឆ្នាំ ពួកគេនឹងមានកំណើនសមត្ថភាពពី៧%ដល់១២% នៅពេលក្លាយខ្លួនជាមនុស្សពេញវ័យ។ ផ្ទុយទៅវិញ ការបាត់បង់ផ្នែកសេដ្ឋកិច្ចជាច្រើននឹងកើតមានឡើង ដោយសារកង្វះខាតលើការវិនិយោគក្នុងកិច្ចគាំពារសង្គមសម្រាប់

ស្ត្រីនិងកុមារដែលងាយរងគ្រោះទាំងនេះ។ ក្នុងករណីមួយផ្សេងទៀត ការសិក្សាលើកុមារអាយុក្រោម៥ឆ្នាំ ដែលពុំបានទទួលការវិវត្តពេញលេញបានបង្ហាញថា ការចំណាយផ្នែកសេដ្ឋកិច្ចចំពោះបញ្ហាសង្គម ស្មើនឹងការ ខាតបង់ចំណូលជាមធ្យមលើសពី២០%ក្នុងមួយឆ្នាំ។ បន្ថែមលើនេះទៀត ការវិភាគស្តីពីប្រសិទ្ធិភាពនៃការ ចំណាយ (អត្រាផលចំណេញនៃការវិនិយោគ) បានរកឃើញនូវផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចដ៏ធំធេងក្នុងការ វិនិយោគដើម្បីលុបបំបាត់ពលកម្មកុមារ។

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានផ្សារភ្ជាប់ការអនុវត្តការគាំពារសង្គម ដើម្បីលើក កម្ពស់គោលការណ៍សមធម៌សង្គម តាមរយៈយន្តការមួយចំនួនដូចខាងក្រោម :

- **ការសម្របសម្រួលការរៀបចំយុទ្ធសាស្ត្រជាតិគាំពារសង្គម** : ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យ កសិកម្ម និងជនបទ តាមរយៈអង្គភាពសម្របសម្រួលយុទ្ធសាស្ត្រជាតិគាំពារសង្គម បានធ្វើការ សម្របសម្រួលអន្តរស្ថាប័ន ដើម្បីធានាឱ្យមានបរិស្ថាននៃការរៀបចំបង្កើតយុទ្ធសាស្ត្រជាតិ គាំពារសង្គមដែលប្រកបដោយលក្ខណៈចំរុះ និងជាប្រព័ន្ធ។ សកម្មភាពមួយចំនួនបានលេចឡើង តាមរយៈយន្តការនេះ រួមមាន :
    - ការជំរុញឱ្យប្រើប្រាស់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ
    - ការលើកកម្ពស់ការអនុវត្តកម្មវិធីដោយរដ្ឋបាលមូលដ្ឋាន
    - ការវិភាគផ្នែកនយោបាយមួយចំនួន ដើម្បីធានាសមាហរណកម្មនៃគោលការណ៍សមធម៌ នៅក្នុងយុទ្ធសាស្ត្រជាតិគាំពារសង្គម
- **ការសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម** : នេះជាយន្តការដែលដើរទន្ទឹមគ្នា ជាមួយនឹងការរៀបចំបង្កើតយុទ្ធសាស្ត្រ នោះគឺការធានាឱ្យមានបរិស្ថាននៃការអនុវត្តយុទ្ធ សាស្ត្រជាតិគាំពារសង្គម ដែលកម្មវិធីគាំពារសង្គម (ដែលកំពុងអនុវត្ត និងដែលត្រូវបង្កើតថ្មី) នឹងត្រូវឆ្លើយតបទៅនឹងបញ្ហាជាឬសគល់នៃភាពក្រីក្រ និងការអភិវឌ្ឍមូលធនមនុស្ស ព្រមទាំង គ្របដណ្តប់លើភាពចន្លោះប្រហោងនៃ ភាពងាយរងគ្រោះ។ សកម្មភាពមួយចំនួនបានលេច ឡើងតាមរយៈយន្តការនេះ រួមមាន
    - កម្មវិធីសមធម៌ (សុខភាព និងអប់រំ)
    - ការផ្តល់ធនធាន និងកម្មសិទ្ធិ (ដីធ្លី និងឡូតិ៍នៃសាទ)
    - កម្មវិធីគាំពារសង្គម (សំណាញ់សុវត្ថិភាពសង្គម)

### រូបទី៦. ទំនាក់ទំនងនៃការគាំពារសង្គម និងសមធម៌




## ៦.១. ការសម្របសម្រួលការរៀបចំយុទ្ធសាស្ត្រជាតិគាំពារសង្គម

### ៦.១.១ ការលើកកម្ពស់សមធម៌តាមរយៈការរៀបចំកម្មវិធីគាំពារសង្គម

**តួនាទីនៃការគាំពារសង្គមនៅក្នុងការលើកកម្ពស់សមធម៌** អាចត្រូវបានឆ្លុះបញ្ចាំងក្នុងអត្ថន័យនៃការរៀបចំកម្មវិធីគាំពារសង្គម ដើម្បីធានាបានថា កម្មវិធីគាំពារសង្គមដែលត្រូវបានរៀបចំដោយរដ្ឋបាលមូលដ្ឋាន ហើយដែលគ្របដណ្តប់លើភាពងាយរងគ្រោះដែលមានជាក់លាក់នៅកម្រិតសហគមន៍ ពិតជាបានលើកកម្ពស់សមធម៌សង្គម។ តាមរយៈគោលដៅនៃកម្មវិធីគាំពារសង្គមនីមួយៗ ភាពផ្សារភ្ជាប់គ្នារវាងតួនាទីនៃការគាំពារសង្គមនិងការលើកកម្ពស់សមធម៌ អាចស្តែងឡើងក្នុងអភិក្រមបីយ៉ាង :

- **ការគាំពារសង្គមបង្កើន "ភាពធន់ទ្រាំ" នៃជនក្រីក្រនិងជនងាយរងគ្រោះចំពោះវិបត្តិនិងភាពងាយរងគ្រោះ** ប្រការនេះអាចកើតមានឡើងតាមរយៈរបបធានារ៉ាប់រងចំពោះជនងាយរងគ្រោះប្រឆាំងទប់ទល់នឹងការធ្លាក់ចុះជាគំហុកនិងភ្លាមៗនៃជីវភាព។ ប្រភពសំខាន់នៃការបង្កើនភាពធន់ទ្រាំនេះ គឺ **កម្មវិធីធានារ៉ាប់រងសង្គម ឬរបបសន្តិសុខសង្គម** ដែលកាត់បន្ថយឱ្យដល់កម្រិតអប្បរមានៃឥទ្ធិពលនៃកលិយុគសេដ្ឋកិច្ច ទៅលើបុគ្គលនិងគ្រួសារ (ឧទាហរណ៍ ការធានារ៉ាប់រង

ពិការភាព របបសោធន)។ កម្មវិធីមួយ ចំនួនទៀត ក៏ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបង្កើនភាពធន់ទ្រាំនៅកម្រិតគ្រួសារ រួមមាន ការធានារ៉ាប់រងសុខភាព និងការធានារ៉ាប់រងកសិកម្ម។ តួនាទីនៃវិស័យឯកជននៅក្នុងកម្មវិធីនេះ គឺជាកត្តាចាំបាច់បំផុត។

- **ការគាំពារសង្គមបង្កើន "សមធម៌" ដោយផ្ទាល់ចំពោះជនក្រីក្រនិងជនងាយរងគ្រោះ** : ប្រការនេះអាចកើតឡើងតាមរយៈការគាំពារចំពោះជនក្រីក្រនិងជនងាយរងគ្រោះ ចំពោះទុក្ខលំបាកនិងវិបត្តិ និងការបង្កើនសមភាពនៃកាលានុវត្តភាព។ **កម្មវិធីជំនួយសង្គមកិច្ច ឬកម្មវិធីសុខមាលភាពសង្គម និងកម្មវិធីសំណាញ់សុវត្ថិភាពសង្គម** (រួមមានកម្មវិធីសង្គហទានសង្គមជាសាច់ប្រាក់និងជាសម្ភារៈ កម្មវិធីផ្តល់អាហារនៅសាលារៀន កម្មវិធីចែកស្បៀងដោយមានគោលដៅ) គឺជាការឆ្លើយតបដោយផ្ទាល់ចំពោះភាពក្រីក្ររ៉ាំរ៉ៃ។ កម្មវិធីទាំងនេះក៏ជួយការពារបុគ្គល និងគ្រួសារក្រីក្រ តាមរយៈការអភិវឌ្ឍមូលធនមនុស្ស (អាហារូបត្ថម្ភ សុខភាព និងការសិក្សាអប់រំ) ដែលដូច្នេះជាការចូលរួមដល់ការកសាងសមភាពនៃកាលានុវត្តភាព
- **ការគាំពារសង្គមបង្កើន "កាលានុវត្តភាព" សម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ** : ប្រការនេះអាចកើតឡើងតាមរយៈការលើកកម្ពស់មូលធនមនុស្សសម្រាប់កុមារនិងយុវជន និងផ្សារភ្ជាប់ជនពេញវ័យធ្វើការងារទាំងអស់ ទៅកាន់មុខរបរនិងការងារដែលមានផលិតភាពខ្ពស់។ ក្នុងអត្ថន័យទីមួយ ការផ្តល់កម្មវិធីគាំពារសង្គមជូនដល់ប្រជាជននៅថ្នាក់មូលដ្ឋាន គឺជា **ការបង្កើតកាលានុវត្តភាពនៃលទ្ធភាពទទួលបានសេវាសាធារណៈនិងសេវាសង្គមកិច្ចដែលចាំបាច់** រួមបញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងហេដ្ឋារចនាសម្ព័ន្ធសង្គម។ ក្នុងអត្ថន័យទីពីរ ការផ្តល់កម្មវិធីគាំពារសង្គមជូនដល់ប្រជាជនក្រីក្រនិងជនងាយរងគ្រោះ គឺជា**ការពង្រីកកាលានុវត្តភាពសម្រាប់ពួកគាត់ ឱ្យចូលរួមកាន់តែប្រសើរជាងមុនក្នុងការអភិវឌ្ឍសេដ្ឋកិច្ច** ការពង្រីកទីផ្សារ និងកម្លាំងពលកម្ម និងជាងនេះទៅទៀត គឺពួកគាត់អាចទទួលមនុញ្ញផលស្មើៗគ្នាពីការអភិវឌ្ឍទាំងនេះ។ ឧទាហរណ៍ **កម្មវិធីសង្គហធានសង្គម** ជាការលើកទឹកចិត្តដល់គ្រួសារក្រីក្រ ឱ្យធ្វើការវិនិយោគលើមូលធនមនុស្ស ដោយបង្កើនតម្រូវការក្នុងវិស័យសិក្សាអប់រំ និងសុខាភិបាល និងដោយជួយដោះស្រាយបញ្ហាវិសមភាពផ្នែកយេនឌ័រ។ **កម្មវិធីសំណង់សាធារណៈ** ជួយដល់ការផ្តល់ប្រាក់និងស្បៀង ដល់ជនក្រីក្រដែលពេញវ័យធ្វើការងារ និងបង្កើតការវិនិយោគលើមូលធនរូបសាស្ត្រក្នុងពេលជាមួយគ្នា។ នៅប្រទេសកម្ពុជា **កម្មវិធីបណ្តុះបណ្តាលជំនាញនិងវិជ្ជាជីវៈ** ក៏ជាការបង្កើតកាលានុវត្តភាពមួយដ៏សំខាន់បន្ថែមទៀត ក្នុងវិស័យសហគ្រិនភាព។ **កម្មវិធីគោល**

**នយោបាយទីផ្សារការងារ** ផ្ដល់លាភការសម្រាប់វិស័យការងារផ្លូវការ និងបង្កើនផលិតភាពការងារដល់កម្មករ។

**រូបទី៧. តួនាទីនៃការគាំពារសង្គមក្នុងការលើកកម្ពស់សមធម៌ ឆ្លុះបញ្ចាំងក្នុងអត្ថន័យនៃការរៀបចំកម្មវិធីគាំពារសង្គម**




ប្រភព World Bank (2012)

## ៦.១.២ សកម្មភាពក្នុងការលើកកម្ពស់សមធម៌តាមរយៈការរៀបចំកម្មវិធីគាំពារសង្គម

### ការជំរុញតួនាទីរដ្ឋបាលមូលដ្ឋានក្នុងការអនុវត្តអន្តរាគមន៍គាំពារសង្គម :

ក្នុងការចូលរួមអនុវត្តយុទ្ធសាស្ត្រគាំពារសង្គមនៅថ្នាក់ក្រោមជាតិ តួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់មានសារៈសំខាន់ និងចាំបាច់ក្នុងការសម្របសម្រួល ធ្វើការពិភាក្សាពិចារណាក្នុងការបញ្ចូលការងារខាងលើឱ្យបានគ្រប់ជ្រុងជ្រោយទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំថ្មី ឬធ្វើបច្ចុប្បន្នភាពនៅក្នុងអាណត្តិថ្មីរបស់ក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត-រាជធានី ក្រុង ស្រុក ខណ្ឌ ដើម្បីជាមូលដ្ឋានក្នុងការអនុវត្តយុទ្ធសាស្ត្រមានប្រសិទ្ធភាពខ្ពស់ និងឆ្លើយទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ជាពិសេសជនក្រីក្រ និងជនងាយរងគ្រោះ ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** បានថ្លែងក្នុងឱកាសប្រកាសដាក់ឱ្យ

អនុវត្តជាផ្លូវការនៃយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ កាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១ ដោយបានសង្កត់លើ "*តួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ មានសារៈសំខាន់ និងចាំបាច់ក្នុងការសម្របសម្រួលការងារអនុវត្តការងារកំណត់មុខសញ្ញាជនក្រីក្រនិងជនងាយរងគ្រោះ ក៏ដូចជាការងារតាមដាននិងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រនេះនៅថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ត្រូវសហការឱ្យបានសកម្មនិងមានប្រសិទ្ធភាពជាមួយក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់រដ្ឋបាលក្រោមជាតិ (គ.ជ.អ.ប) ដើម្បីពង្រឹងតួនាទីភារកិច្ច និងសមត្ថភាពរបស់មន្ត្រីថ្នាក់ក្រោមជាតិ ក្នុងការបំពេញភារកិច្ចចូលរួមចំណែកអនុវត្តយុទ្ធសាស្ត្រគាំពារសង្គមនេះឱ្យមានប្រសិទ្ធភាព*"។

**គោលដៅសំខាន់នៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺការលើកកម្ពស់សុខមាលភាព (ទាំងសម្លេង ទាំងសិទ្ធិ និងជីវភាពរស់នៅ) របស់ប្រជាពលរដ្ឋ ការលើកកម្ពស់សមភាពរវាងប្រជាពលរដ្ឋនៅក្នុងសហគមន៍ និងការធានានូវយុត្តិធម៌ក្នុងការទទួលបានសេវាសាធារណៈ**។ ការកែលម្អ និងការផ្លាស់ប្តូរឥរិយាបទនៃភាពជាតំណាង ព្រមទាំងការផ្តល់ឱកាសចូលរួមជាសម្លេង ជាសិទ្ធិដល់ប្រជាពលរដ្ឋកាន់តែទូលំទូលាយ ក្នុងការប្រាស្រ័យទាក់ទងជាមួយតំណាងរបស់ខ្លួន និងការជម្រុញឱ្យមានគណនេយ្យភាពកាន់តែខ្លាំងឡើងរបស់ក្រុមប្រឹក្សានិងមន្ត្រីនានាចំពោះប្រជាពលរដ្ឋ នឹងបង្កើននូវ**មូលធនសង្គម** និងការផ្សារភ្ជាប់គ្នានៅសហគមន៍ គឺជាធាតុចូលដ៏មានសារសំខាន់ និងមានប្រសិទ្ធភាពក្នុងដំណើរការអភិវឌ្ឍសង្គមជាតិ ឱ្យបានរុងរឿងគ្រប់វិស័យទៅអនាគត។ ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំសង្កាត់ ក៏បានបង្ហាញនូវលទ្ធផលជាវិជ្ជមានគួរឱ្យកត់សម្គាល់ ក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ការពង្រឹងអភិបាលកិច្ចល្អ ការកែលម្អគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន។

នៅឆ្នាំ២០១២ កំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានឈានចូលក្នុងដំណាក់កាលកាន់តែស៊ីជម្រៅថែមទៀត។ រចនាសម្ព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំឡើងវិញ ស្របតាមគោលការណ៍ដែលបានចែងក្នុងច្បាប់រៀបចំអង្គការកម្មវិធីជាតិរយៈពេល១០ឆ្នាំ និងផែនការអនុវត្តរយៈពេល៣ឆ្នាំដំបូង នៃកម្មវិធីជាតិនេះ។ សមិទ្ធផលដែលបានសម្រេចមានជាអាទិ៍:

- ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការធ្វើសមាហរណកម្មមន្ត្រីរាជការនៅក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្មី
- ការបណ្តុះបណ្តាលកសាងធនធានមនុស្ស
- ការរៀបចំច្បាប់ស្តីពីរបបហិរញ្ញវត្ថុ
- និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយមូលនិធិក្រុង-ស្រុកត្រូវបាន បង្កើតនិងដាក់ឱ្យដំណើរការ ។

រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ក៏បានរៀបចំនូវផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល លើមូលដ្ឋាននៃការចូលរួមតាមបែបប្រជាធិបតេយ្យ ។

ការការពារ និងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចការអភិវឌ្ឍន៍ មានសារសំខាន់ជាយុទ្ធសាស្ត្រ។ ក្នុងបរិការនេះ ទាមទារនូវការពង្រឹងសន្តិភាព និងប្រសិទ្ធភាពនៃស្ថាប័នជាតិនិងថ្នាក់ក្រោមជាតិ រួមមានប្រសិទ្ធភាពការងារ តម្លាភាព និងគណនេយ្យភាព និងសន្តិភាពសង្គមមានយុត្តិធម៌ និងសមភាព ដែលការពារនិងលើកកម្ពស់គោលការ សិទ្ធមនុស្ស និងលុបបំបាត់អំពើហឹង្សាគ្រប់រូបភាព។ របៀបវារៈនេះនឹងត្រូវបង្កើតការងារធ្វើអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បង្កើនផលិតភាពការងារ កែលម្អភាពប្រណាំងប្រជែង និងលើកកម្ពស់ការផលិត និងការប្រើប្រាស់ក្របដោយចិរភាព។ ការផ្តល់កាលានុវត្តភាពដល់ស្ត្រី និងកុមារ ការវិនិយោគលើការអភិវឌ្ឍន៍ធនធាន មនុស្សក្នុងវ័យយុវជន និងពង្រីកវិសាលភាពនៃការគាំពារសង្គម និងធានានៃការផ្តលសេវាសិក្សាអប់រំ និងសុខភាព គឺជារបៀបវារៈដ៏មានសារសំខាន់ចាំបាច់ក្នុងការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងសមធម៌[9] ។

ទិសដៅនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ គឺដើម្បីបង្កើត និងលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប ២០១០)។ វិមជ្ឈការមានន័យថា រាជរដ្ឋាភិបាលប្រគល់នូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ឱ្យទៅក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ដូចជា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សា

9 UN "Communiqué from the Meeting of the High-level Panel of Eminent Persons on the Post-2015 Development Agenda in Monrovia, Liberia". Monrovia, 1 February 2013.

ក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន។ វិសហមជ្ឈការមានន័យថា រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នផ្ទេរប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយដើម្បីអនុវត្តមុខងារនោះ ក្នុងនាមរាជរដ្ឋាភិបាល ក្រសួង ឬស្ថាប័ននោះ។ ក្នុងន័យនេះភាពជាម្ចាស់ មិនបានផ្តល់ជូនអង្គភាពក្រោមបង្គាប់ឬក្រុមប្រឹក្សាឡើយ។ រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលបានរក្សាទុកនូវភាពជាម្ចាស់នោះ។ រាជរដ្ឋាភិបាលចាត់ទុកកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការបង្វិតសេវាសាធារណៈឱ្យកាន់តែទៅជិតប្រជាពលរដ្ឋ ហើយរំពឹងថានឹងទទួលបាននូវផលប្រយោជន៍ធំៗចំនួនបីដូចខាងក្រោម :

- ទី១ : ប្រជាពលរដ្ឋអាចមានលទ្ធភាពចូលរួមយ៉ាងសកម្មនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋាន ដែលនេះគឺជាការពង្រឹងនិងពង្រីកនូវការចូលរួមជាសាធារណៈ នៅក្នុងការអភិវឌ្ឍប្រទេសជាតិ។ ផ្អែកលើលទ្ធផលនៃការចូលរួមនេះ តម្រូវការ និងអាទិភាពនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ត្រូវបានគិតគូរយកចិត្តទុកដាក់ និងឆ្លើយតបកាន់តែប្រសើរឡើង។ ដូច្នេះតាមរយៈការអនុវត្តកំណែទម្រង់នេះ នឹងនាំឱ្យមានការធ្វើសេចក្តីសម្រេចចិត្តកាន់តែមានភាពល្អប្រសើរ និងការប្រើប្រាស់ធនធានកាន់តែមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិថែមទៀត
- ទី២ : ការផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិកាន់តែរហ័ស និងមានប្រសិទ្ធភាព ព្រោះអ្នកទទួលខុសត្រូវក្នុងការផ្តល់សេវាទាំងនោះត្រូវបានផ្ទេរ ឬបង្វិតឱ្យទៅជិតប្រជាពលរដ្ឋ
- ទី៣ : ការបង្កើននូវលទ្ធភាពនៃការកៀរគរប្រភពធនធាននៅមូលដ្ឋានសម្រាប់ផ្តល់សេវា និងការអភិវឌ្ឍបន្ថែមទៀត ដោយផ្អែកលើឆន្ទៈនៃការចូលរួមរបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល ក៏ដូចជាការកៀរគរធនធានរបស់វិស័យឯកជននានា ឱ្យចូលរួមជាមួយធនធានរបស់អាជ្ញាធរមូលដ្ឋានក្នុងការវិនិយោគលើការអភិវឌ្ឍមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។

ដូច្នេះ ដើម្បីឆ្លើយតបទៅនឹងគោលដៅជាយុទ្ធសាស្ត្រខាងលើ កំណែទម្រង់ចាំបាច់ត្រូវរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ ក្នុងគោលបំណងដើម្បី :

- ធានាឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងទូលំទូលាយ សំដៅពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ជាខឿនសេដ្ឋកិច្ចនៅមូលដ្ឋាន

- ធានាឱ្យប្រជាពលរដ្ឋគ្រប់រូបអាចមានឱកាសស្មើគ្នាក្នុងការចូលរួមរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន
- បង្កើតនូវបរិយាកាសប្រកបដោយប្រសិទ្ធភាព សម្រាប់គ្រប់គ្រងធនធានធម្មជាតិ និងសម្រាប់ការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើជនក្រីក្រ ក្រុមជនងាយរងគ្រោះ ជនជាតិដើម ជនជាតិភាគតិច ស្ត្រី និងកុមារ យុវជន យុវនារី...។

## ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ

ការផ្តល់កម្មវិធីគាំពារសង្គម ត្រូវផ្តោតការយកចិត្តទុកដាក់ និងតម្រង់ទិសឱ្យចំដល់គ្រួសារក្រីក្រ និងងាយរងគ្រោះបំផុត។ យន្តការជ្រើសរើសនិងកំណត់អត្តសញ្ញាណអ្នកទទួលផលលាភការ ពីកម្មវិធីគាំពារសង្គម មានសារៈសំខាន់បំផុតសម្រាប់ការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គមប្រកបដោយប្រសិទ្ធិភាព និងភាពសក្តិសិទ្ធិក្នុងការចំណាយ។ វិធីសាស្ត្រមួយចំនួន ក្នុងការជ្រើសរើសអ្នកទទួលផលសម្រាប់អន្តរាគមន៍គាំពារសង្គម រួមមាន**វិធីសាស្ត្រកំណត់អត្តសញ្ញាណដោយអ្នកទទួលផលខ្លួនឯង តាមលក្ខណៈភូមិសាស្ត្រ** និង**គ្រួសារ**។ **ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ** នឹងត្រូវប្រើប្រាស់ជាចម្បងនូវបញ្ជីគ្រួសារក្រីក្រ និងសមាជិករបស់គ្រួសារទាំងនេះ ដែលបានបង្កើតដោយ **កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ** នៃក្រសួងផែនការ។

## ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ

ជាកត្តាចាំបាច់បំផុតដើម្បីធានាថា គោលការណ៍សមធម៌នឹងត្រូវ ធ្វើសមាហរណកម្មនៅក្នុងអន្តរាគមន៍គាំពារសង្គម និងដើម្បីតាមដានថាគម្លាតនៃការអភិវឌ្ឍមូលធនមនុស្ស និងភាពក្រីក្រ នឹងត្រូវកាត់បន្ថយ។ ការរៀបចំចងក្រង **ក្របខណ្ឌនៃការពិនិត្យតាមដានការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គមនៅកម្ពុជា** បានរៀបចំឡើងដោយយោងតាមអនុសាសន៍របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ ដែលបានលើកឡើងថាការពិនិត្យតាមដាន និងវាយតម្លៃលើអន្តរាគមន៍កម្មវិធី និងយុទ្ធសាស្ត្រទាំងមូល ជាតម្រូវការចាំបាច់សម្រាប់ការវិភាគលើការគាំពារសង្គមនៅកម្ពុជា។ ការពិនិត្យតាមដាននិងវាយតម្លៃលើកម្មវិធីតាមវិស័យ ជាតួនាទីនិងភារកិច្ច របស់ក្រសួង-ស្ថាប័នជំនាញ ដែលបានកំណត់សូចនាករ និងកំពុងអនុវត្ត។ ដោយឡែក ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ក៏នឹងរៀបចំការត្រួតពិនិត្យឯករាជ្យលើការ

អនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គមដើម្បីគាំទ្រដល់ការពិភាក្សា ដោយមានព័ត៌មានពិតប្រាកដលើការសម្រប សម្រួលទូទៅ និងការរៀបចំយុទ្ធសាស្ត្រនៅពេលបន្តទៀត។

**រូបទី៨. ការប្រើប្រាស់ក្របខណ្ឌពិនិត្យតាមដានដោយផ្អែកលើលទ្ធផល នៅក្នុងយុទ្ធសាស្ត្រជាតិគាំពារសង្គម**




សូចនាករដែលបានលើកឡើងក្នុងឯកសារ **ក្របខណ្ឌនៃការពិនិត្យតាមដានការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គមនៅកម្ពុជា** ត្រូវបានកំណត់ឡើងដោយមានការពិចារណាប្រៀបធៀបផ្ទួរផ្គងទៅនឹង **មូលធនជាមូលដ្ឋានទាំង៥** ដែលមនុស្សគ្រប់រូបត្រូវមាន ដើម្បីរារាំងកុំឱ្យធ្លាក់ចូលទៅក្នុងភាពក្រីក្រ និងការរក្សានិរន្តរភាពនៃជីវភាព រួមមាន ៖

- **មូលធនហិរញ្ញវត្ថុ** ដែលជាធនធានហិរញ្ញវត្ថុដែលប្រជាជនត្រូវប្រើប្រាស់ដើម្បីសម្រេចឱ្យបាននូវគោលដៅជីវភាពរបស់ពួកគាត់
- **មូលធនធម្មជាតិ** ដែលជាធនបម្រុងធម្មជាតិ ដែលទទួលបានពីរំហូរនៃធនធាន និងសេវាកម្ម (ដូចជា វដ្តនៃសារធាតុចិញ្ចឹម ការការពារសំណឹក...) សម្រាប់កំណើនជីវភាព
- **មូលធនសង្គម** ជាធនធានរបស់សង្គមទាំងមូល ដែលប្រជាជនត្រូវបង្កើតនិងពឹងផ្អែកក្នុងពេលព្រមគ្នា ដើម្បីគោលដៅជីវភាព
- **មូលធនរូបសាស្ត្រ** រួមមានហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងទ្រព្យសម្បត្តិសកម្ម ដែលចាំបាច់សម្រាប់ការអភិវឌ្ឍជីវភាព

- មូលធនមនុស្ស គឺជាជំនាញ ចំណេះដឹង លទ្ធភាពពលកម្ម និងសុខភាព ដែលរួមគ្នាអនុញ្ញាតឱ្យប្រជាជន អាចស្វែងរកឃើញយុទ្ធសាស្ត្រជីវភាពបានផ្សេងៗគ្នា

## ការសិក្សាលើអត្រាផលចំណេញនៃការវិនិយោគលើការគាំពារសង្គម

ការសិក្សានេះ ជាការកំណត់រក **"ឯកសារផែនការវិនិយោគ"** លើការគាំពារសង្គមដើម្បីរកឱ្យឃើញពីផលចំណេញលើរាល់ឯកត្តានៃការវិនិយោគលើកម្មវិធីគាំពារសង្គម។ ការសិក្សានេះ បង្ហាញពីនិទស្សន៍លើថ្ងៃអនាគត ស្តីពីពិធកម្មនិងផលិតភាពនៃកម្លាំងពលកម្ម និងការកែសម្រួលរចនាសម្ព័ន្ធកម្លាំងពលកម្មកម្ពុជា តាមរយៈការគាំពារសង្គម។ ក្នុងរយៈពេលនៃការរៀបចំយុទ្ធសាស្ត្រជាតិគាំពារសង្គមកន្លងមក មានហេតុផលជាច្រើន ជាពិសេសតម្រូវការបន្ថែមលើការទ្រទ្រង់ថវិកាជាតិលើសកម្មភាពអនុវត្តដែលត្រូវបញ្ជាក់ថា **"ការគាំពារសង្គមជាការវិនិយោគសម្រាប់ការអភិវឌ្ឍន៍ជាតិ ជួយដល់ការកាត់បន្ថយភាពក្រីក្រ បង្កើនកម្រូចការនិងការពង្រីកទីផ្សារ និងជួយដល់ការកសាងធនធានមនុស្ស មានសុខភាពបរិបូណ៌ មានការសិក្សាចំណេះដឹង ជំនាញខ្ពស់ និងមានកម្លាំងផលិតភាពគ្រប់គ្រាន់"**។

រូបទី៩. ម៉ូដែលនៃការសិក្សាអត្រាផលចំណេញនៃការវិនិយោគលើការគាំពារសង្គម នៅក្នុងភាពក្រីក្រនិងសមធម៌



ការវិនិយោគ ឬការដាក់ទុន ទៅលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមានផ្លូវគមនាគមន៍ ប្រឡាយធារាសាស្ត្រ ឬការផលិតកសិផល ឬការធ្វើជំនួញជាដើម អាចអនុញ្ញាតឱ្យមានទិន្នន័យគ្រប់គ្រាន់សម្រាប់ធ្វើការគណនាជាអត្រាផលចំណេញសេដ្ឋកិច្ចបានក្នុងរយៈពេលខ្លីបាន។ ដោយឡែកការវិនិយោគលើវិស័យសង្គម ដើម្បីទទួលផលត្រឡប់មកវិញគឺត្រូវប្រើរយៈពេលវែង ទើបអាចកំណត់ផលសេដ្ឋកិច្ចផង និងផលសង្គមផង ហើយបានត្រឹមតែជាការប្រៀបធៀបប៉ុណ្ណោះ។ ព្រោះថាការវិនិយោគលើការគាំពារសង្គមមានឥទ្ធិពលលើជីវភាពរស់នៅរបស់គ្រួសារ ម្យ៉ាងអាចជួយសម្រាលឬកាត់បន្ថយភាពក្រីក្រផង និងមានឥទ្ធិពលលើស្ថានភាពសុខភាព លើអាហារូបត្ថម្ភ លើការសិក្សាអប់រំ និងការសម្រេចចិត្តលើមុខរបរចិញ្ចឹមជីវិតដែលឈានទៅការបង្កើនមូលធនមនុស្ស និងប្រសិទ្ធិភាពផលិតកម្ម។

ការវាស់ស្ទង់ផលនៃការវិនិយោគ មានច្រើនដំណាក់កាល។ ឧទាហរណ៍ ការផ្តល់អាហារូបករណ៍ដល់សិស្ស ការផ្តល់ការសិក្សាដល់កុមារ ការចិញ្ចឹមកុមាររហូតដល់វ័យធំ ឱ្យក្លាយជាពលរដ្ឋមានសុខភាពរឹងមាំ មានចំណេះដឹង គ្រប់គ្រាន់ ប្រាជ្ញាឈ្លាសវៃ ជាទុនសង្គម ជាគុណសម្បត្តិរបស់គ្រួសារ និងសង្គមជាតិទៅអនាគត ត្រូវការពេលវេលា សមត្ថភាព និងលទ្ធភាពមធ្យោបាយជាច្រើន ជារូបវន្តផង និងអរូបវន្តផង។ ការគណនាឬប៉ាន់ស្មានលើអត្រាផលចំណេញ ជាការពិបាកនិងស្មុគស្មាញ ម្យ៉ាងសេដ្ឋកិច្ចវិទូមានការពិបាកនឹងទទួលយកបាន។ យើងអាចគ្រាន់តែនិយាយថា នៅក្នុងសង្គមមួយដែលមិនមានអ្នកចេះដឹង ប្រជាពលរដ្ឋមិនមានសុខភាព គ្មានកម្លាំងពលំមាំមួន សង្គមនោះមិនអាចអភិវឌ្ឍទៅមុខបានយូរអង្វែងទេ។

## ៦.២. ការសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម

### ៦.២.១ ការលើកកម្ពស់សមធម៌តាមរយៈការអនុវត្តកម្មវិធីគាំពារសង្គម

ម្យ៉ាងវិញទៀត **តួនាទីនៃការគាំពារសង្គមនៅក្នុងការលើកកម្ពស់សមធម៌ អាចត្រូវបានឆ្លុះបញ្ចាំងក្នុងអត្ថន័យនៃការអនុវត្តកម្មវិធីគាំពារសង្គម** ដើម្បីធានាបានថា កម្មវិធីគាំពារសង្គមនឹងត្រូវអនុវត្តប្រកបដោយតម្លាភាព និងមានគណនេយ្យភាព តាមរយៈរដ្ឋបាលមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ចំពោះប្រជាជននៅថ្នាក់មូលដ្ឋាន ដែលជាអ្នកកំណត់តម្រូវការ។ ការអនុវត្តកម្មវិធីគាំពារសង្គមដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិគាំពារសង្គម នឹងធ្វើឡើងនៅថ្នាក់មូលដ្ឋាន ហើយអនុវត្តដោយរដ្ឋបាលមូលដ្ឋាន។ តាមរយៈការអនុវត្តកម្មវិធីគាំពារសង្គម ការរៀបចំកែលំអស្ថាប័ន នឹងត្រូវធ្វើឡើង **"នវានុវត្តនៃស្ថាប័ន"** ចាប់តាំងពីកម្រិតគ្រួសារ សហគមន៍មូលដ្ឋាន រហូតដល់កម្រិតថ្នាក់ជាតិ។ តាមរយៈផលប៉ះពាល់ដែលអាចកើតមាននៅ

គ្រប់កម្រិតទាំងបីខាងលើ (គ្រួសារ សហគមន៍មូលដ្ឋាន និងថ្នាក់ជាតិ) ការគាំពារសង្គមគឺជាឧបករណ៍មួយយ៉ាងចាំបាច់ ដើម្បីធានាដល់ការចូលរួមប្រកបដោយសមធម៌ និងសមភាព ពីរវាងស្ថាប័នពាក់ព័ន្ធទាំងអស់។

**រូបទី១០. តួនាទីនៃការគាំពារសង្គមក្នុងការលើកកម្ពស់សមធម៌ ឆ្លុះបញ្ចាំងក្នុងអត្ថន័យនៃការអនុវត្តកម្មវិធីគាំពារសង្គម**




ប្រភព Aldermann and Ruslan (2012)

## ៦.២.២សកម្មភាពក្នុងការលើកកម្ពស់សមធម៌តាមរយៈការអនុវត្តកម្មវិធីគាំពារសង្គម

### ការរៀបចំបែងចែកធនធានប្រកបដោយសមធម៌ដល់ប្រជាជន

សកម្មភាពនេះ គឺជាប្រភេទអន្តរាគមន៍មួយនៃការគាំពារសង្គម ដែលផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងដល់សមធម៌សម្រាប់ជនក្រីក្រ។ ជាមួយនឹងការដាក់ចេញនូវយុទ្ធសាស្ត្រគាំពារសង្គម រាជរដ្ឋាភិបាល ក៏បានធ្វើការសម្រេចជាយុទ្ធសាស្ត្រនូវការប្រកាសលុបចោលឡូត៍នេសាទទូទាំងប្រទេស ដែលជាកំណែទម្រង់ផ្តាច់ព្រ័ត្ត កាលពីថ្ងៃទី៨ ខែមិនា ឆ្នាំ២០១២ ដោយមិនឱ្យមានឡូត៍ធ្វើអាជីវកម្មនេសាទជាបន្តទៀត និងការផ្តល់ដីសម្បទានជូនប្រជាពលរដ្ឋក្រីក្រ ដែលខ្វះដីបង្កបង្កើនផល (**គោលនយោបាយចាស់**

**សកម្មភាពថ្មី**)។ ថ្មីៗនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈ**គ្រុមការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភថ្នាក់ជាតិ** បានពិនិត្យពិភាក្សាលើ សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត "**ប្រព័ន្ធស្បៀងបម្រុងកម្ពុជា**" ដើម្បីត្រៀមផ្គត់ផ្គង់ស្បៀង (ជាអង្ករ ១៦,០០០ តោន) ជាបន្ទាន់ដល់ជនរងគ្រោះ ក្នុងគ្រាមានគ្រោះមហន្តរាយ ឬគ្រោះអាសន្ននានា កើតឡើងក្នុងប្រទេសកម្ពុជា និងត្រៀមគ្រាប់ពូជស្រូវ (៣,០០០តោន) បន្លែដំណាំរួមផ្សំផ្សេងៗទៀត (៥០តោន) ដើម្បីស្តារឡើងវិញក្រោយពេល មានគ្រោះមហន្តរាយ ឬគ្រោះអាសន្ន។

## មូលនិធិសមធម៌សុខភាព

មូលនិធិសមធម៌សុខាភិបាល គឺជាអន្តរាគមន៍ដែលមានសារៈប្រយោជន៍ចម្បង ដែលធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាជនក្រីក្របានប្រសើរឡើង ដោយផ្តល់ជូនពួកគាត់នូវគុណភាពសេវាសុខភាពដោយលើកលែងការបង់ប្រាក់។ បើសិនជាមិនមានមូលនិធិសមធម៌សុខភាពនោះទេ នៅពេលដែលសមាជិកណាម្នាក់នៅក្នុងគ្រួសារក្រីក្រមានជំងឺ គឺធ្វើឱ្យពួកគាត់មានភាពលំបាកយ៉ាងខ្លាំងក្នុងការស្វែងរកប្រាក់មកព្យាបាលជំងឺ។ ប្រសិនបើពួកគាត់គ្មានប្រាក់ នោះពួកគាត់នឹងមិនយកអ្នកជំងឺទៅមណ្ឌលសុខភាពទេ។ មូលនិធិសមធម៌សុខភាព គឺជាយន្តការហិរញ្ញវត្ថុខាងផ្នែកតម្រូវការ ដើម្បីឱ្យប្រជាជនក្រីក្រទទួលបានសេវាសុខភាពប្រកបដោយសមធម៌កាន់តែប្រសើរឡើង។ បច្ចុប្បន្ននេះ មូលនិធិសមធម៌សុខភាព ប្រើសម្រាប់បង់ថ្លៃព្យាបាលអ្នកក្រីក្រ នៅពេលដែលពួកគាត់ទៅរកសេវាព្យាបាលនៅមន្ទីរពេទ្យ (កញ្ចប់បន្ថែមនៃសកម្មភាពសេវាសុខភាពផ្សេងៗ) និងបង់ថ្លៃធ្វើដំណើរ និងថ្លៃម្ហូបអាហារផ្សេងៗ។

### ប្រអប់ទី២. គោលការណ៍នៃមូលនិធិសមធម៌សុខាភិបាល

- *មូលនិធិសមធម៌សុខាភិបាល ចំណាយទៅលើមន្ទីរពេទ្យ និងមណ្ឌលសុខភាពនានាមួយចំនួន ដើម្បីផ្តល់នូវការថែក្សាសុខភាពទៅដល់គ្រួសារក្រីក្រ*
- *ក្នុងការធ្វើសហប្រតិបត្តិការនៅមន្ទីរពេទ្យ និងមណ្ឌលសុខភាព គ្រួសារក្រីក្រមិនបាច់បង់ប្រាក់សម្រាប់សេវានានាក្នុងការថែរក្សាសុខភាពឡើយ*
- *មូលនិធិសមធម៌សុខភាព ក៏ត្រូវបង់ថ្លៃធ្វើដំណើរ និងថ្លៃម្ហូបអាហារសម្រាប់គ្រួសារក្រីក្រ*

## កម្មវិធីគាំពារសង្គមផ្សេងទៀត

អាស្រ័យតាមលក្ខណៈនៃការរៀបចំកម្មវិធី អន្តរាគមន៍គាំពារសង្គមនីមួយៗ មានលទ្ធផលក្នុងគោលដៅខុសៗគ្នាទៅលើសូចនាករផ្នែកជីវភាព និងការអភិវឌ្ឍមនុស្ស ប៉ុន្តែដែលមានអភិក្រមរួមគ្នា ឆ្ពោះទៅកាន់ការសម្រេចបាននូវសមធម៌។ **កម្មវិធីសង្គហធានសង្គមសម្រាប់ស្ត្រីមានផ្ទៃពោះនិងកុមារ** ស្ថិតនៅក្នុងលំដាប់ជាអាទិភាពបំផុត នៃការកសាង **"សមធម៌ពីកំណើត"** ដល់កុមារក្រីក្រ អោយមានការលូតលាស់សុខភាព បញ្ញាស្មារតី និងអាហារូបត្ថម្ភ ដូចកុមារដទៃ។ ការវិនិយោគតាមរយៈការឧបត្ថម្ភដល់កុមារនៅអាយុ១០០០ថ្ងៃដំបូង ជាការវិនិយោគផ្នែកគាំពារសង្គមសម្រាប់កុមារមួយជីវិត។ **កម្មវិធីផ្តល់អាហារនៅសាលារៀន** ក្នុងលក្ខណៈជាអាហារពេលព្រឹក សម្រាប់កុមារនៅថ្នាក់បឋមសិក្សាមុនពេលចូលរៀន មានផលប៉ះពាល់យ៉ាងធំធេងដល់ការលើកទឹកចិត្តកុមារ អោយមកសាលារៀនយ៉ាងទៀងពេលវេលា មានអារម្មណ៍អង្គុយរៀនក្នុងថ្នាក់ដោយពុំឃ្លានអាហារ ហើយក្នុងករណីមួយចំនួនគឺកុមារជាបងបាននាំប្អូនមកជាមួយដើម្បីទទួលទានអាហារ។ ការលើកកម្ពស់លទ្ធផល នៃការសិក្សា កម្រិតអាហារូបត្ថម្ភ បញ្ញាស្មារតី និងសាមគ្គីភាពរវាងកុមារ គឺជាការកាត់បន្ថយឧបសគ្គនៃការសម្រេចចិត្តចូលរបស់កុមារ ដែលមានផលប៉ះពាល់វិជ្ជមានយ៉ាងធំធេងសម្រាប់ពួកគេ។ ឧទាហរណ៍មួយទៀត គឺ **កម្មវិធីសំណង់សាធារណៈ** ដែលផ្តោតគោលដៅលើជនពេញវ័យការងារក្រីក្រ ដែលជួបប្រទះបញ្ហានិកម្មភាពជាលក្ខណៈរដូវកាល។ ការចូលរួមក្នុងកម្មវិធីនេះ ជាការសម្រាលបន្ទុកលើអសន្តិសុខផ្នែកប្រាក់ចំណូលសម្រាប់គ្រួសារ ហើយក៏ជាការចូលរួមរបស់ប្រជាជនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសម្រាប់សហគមន៍ផ្ទាល់។

## ៧. សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេល ៦០ឆ្នាំកន្លងមក ប្រទេសកម្ពុជា បានឆ្លងកាត់នូវដំណាក់កាលជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាច្រើន ប្រកបដោយភាពបត់បែន និងលំបាកស្មុគស្មាញជាទីបំផុត។ ជាការកត់សម្គាល់ ក្នុងរយៈពេល ២០ឆ្នាំម្តងៗ ស្ថានភាពនយោបាយប្រទេសមានការប្រែប្រួល ហើយបានកំណត់ជោគវាសនាប្រទេសរយៈពេល២០ឆ្នាំទៅមុខទៀត។ ឆ្នាំ២០១២ ចាត់ជាឆ្នាំពិសេសរបស់កម្ពុជា ដែលត្រូវកត់ត្រាទុកជាប្រវត្តិសាស្ត្រនៃការអភិវឌ្ឍន៍ ប្រទេសឆ្ពោះទៅកាន់ភាពចំរុងចម្រើនរុងរឿងលើគ្រប់វិស័យក្នុង **សម័យសម្តេចអគ្គមហាសេនាបតីតេជោ** នៃសតវត្សទី២១នេះ ដែលនឹងកំណត់ជោគវាសនារបស់កម្ពុជាសម្រាប់ឆ្នាំ២០៣០ ជាមួយនិងទស្សនទានថ្មីនៃការអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយនៅក្រោយឆ្នាំ២០១៥ នៃការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្ស ពោលគឺឆ្ពោះទៅកាន់ការ**អភិវឌ្ឍន៍បៃតងប្រកបដោយចីរភាព និងសមធម៌**។

នៅក្នុងរបាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ២០១០[10] រៀបចំដោយអង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ បានលើកឡើងថា លុយមានប្រយោជន៍ ប៉ុន្តែភស្តុតាងជាក់ស្តែងបានបង្ហាញប្រាប់ថា ការរីកចម្រើនគ្រប់យ៉ាងនឹងអាចសម្រេចបាន ដោយការអភិវឌ្ឍន៍វិស័យជាច្រើន ដោយមិនចាំបាច់បោះទុនសម្រាប់តែកំណើនសេដ្ឋកិច្ចតែមួយមុខនោះទេ ។

អន្តរាគមន៍ដែលផ្តល់ជូនប្រជាជនក្រីក្រនិងងាយរងគ្រោះ ក្នុងរូបភាពជាកម្មវិធីគាំពារសង្គម បានបង្ហាញភស្តុតាងយ៉ាងជាក់ច្បាស់ ទាំងក្នុងបរិបទអន្តរជាតិ និងទាំងនៅកម្ពុជា នូវឥទ្ធិពលទៅលើការកាត់បន្ថយភាពក្រីក្រ និងសូចនាករនៃការអភិវឌ្ឍមូលធនមនុស្ស។ យុទ្ធសាស្ត្រជាតិគាំពារសង្គម បានដាក់ចេញជាយុទ្ធសាស្ត្រក្នុងដំណាក់កាលខ្លី និងវែង និងដែលមានលក្ខណៈចំរុះនិងជាប្រព័ន្ធ ដើម្បីតម្រង់ទៅរកសមធម៌សង្គម ដែលជាការបង្កើនការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងក្នុងរយៈពេលវែង។ ការដាក់សមធម៌ឱ្យនៅចំកណ្តាលនៃកម្មវិធីអភិវឌ្ឍ គឺជាការឆ្លើយតបទៅនឹង តម្រូវការនៃកំណើននិងការអភិវឌ្ឍសេដ្ឋកិច្ចដោយមានការចូលរួម។

រាជរដ្ឋាភិបាល តាមរយៈក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ នឹងបន្តលើកកម្ពស់របៀបវារៈ នៃការគាំពារសង្គមឱ្យជាអាទិភាពសម្រាប់ការអភិវឌ្ឍសង្គម។ យន្តការសម្របសម្រួលលើការរៀបចំនិងការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម នឹងជាកត្តាគន្លឹះបំផុត ដើម្បីធានាដល់តួនាទីរបស់ការគាំពារសង្គមក្នុងការជំរុញនិងការលើកកម្ពស់សមធម៌ តាមរយៈទិដ្ឋភាពចំនួនពីរ គឺក្នុងអត្ថន័យនៃការរៀបចំកម្មវិធីគាំពារសង្គម (ពិសេសការគ្របដណ្តប់លើភាពងាយរងគ្រោះដែលកើតមានក្នុងវដ្តជីវិត) និងក្នុងអត្ថន័យនៃការអនុវត្តកម្មវិធីគាំពារសង្គម (ដែលតម្រូវឱ្យមាននវានុវត្តផ្នែកស្ថាប័ន ពីថ្នាក់គ្រួសារ សហគមន៍មូលដ្ឋាន និងថ្នាក់ជាតិ)។ សកម្មភាពសំខាន់ៗក្នុងការរៀបចំកម្មវិធីគាំពារសង្គម អាចរំលេចនៅក្នុងការជំរុញឱ្យប្រើប្រាស់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ការលើកកម្ពស់ការអនុវត្តកម្មវិធីដោយរដ្ឋបាលមូលដ្ឋាន និងការវិភាគផ្នែកនយោបាយមួយចំនួនដើម្បីធានាសមាហរណកម្មនៃគោលការណ៍សមធម៌ នៅក្នុងយុទ្ធសាស្ត្រជាតិគាំពារសង្គម។ សកម្មភាពសំខាន់ៗក្នុងការអនុវត្តកម្មវិធីគាំពារសង្គម គឺត្រូវធ្វើទន្ទឹមគ្នា

[10] *'Money matters, but the evidence shows overwhelmingly that great improvements can be achieve in other aspects of development without going flat out for economic growth" – (UNDP 2010 Human Development Report).*

ជាមួយនឹងការរៀបចំបង្កើតយុទ្ធសាស្ត្រ រួមមានកម្មវិធីសមធមិ (សុខភាព និងអប់រំ) ការផ្តល់ធនធាននិងកម្មសិទ្ធិ (ដីធ្លី និងឡូតិ៍នៃសាទ) និងកម្មវិធីគាំពារសង្គម ។

# ឯកសារពិគ្រោះ


គ.ជ.អ.ប. (គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ). ២០១២. សៀវភៅណែនាំស្តីពីការលើកកម្ពស់សេវាសង្គមប្រកបដោយសមធម៌. ភ្នំពេញ. កម្ពុជា

គ.ជ.អ.ប. (គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ). ២០១០. សេចក្តីព្រាងសៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលខេត្ត. លេខាធិការដ្ឋាន គ.ជ.អ.ប. ភ្នំពេញ. កម្ពុជា

ព្រះភិក្ខុធម្មបាល ខៀវ ជុំ .១៩៧២. សកលចិន្តា. បោះពុម្ពនៅរាជធានីភ្នំពេញ

រាជរដ្ឋាភិបាលកម្ពុជា. ២០០៨. យុទ្ធសាស្រ្តចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាព. ប្រសាសន៍របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី. ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា. ២០០៩. ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣. ក្រសួងផែនការ ភ្នំពេញ. កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា. ២០១១. យុទ្ធសាស្រ្តជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះនៅកម្ពុជា. ទទួលការអនុម័តក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១១. ភ្នំពេញ កម្ពុជា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី. ២០១៣. សុន្ទរកថាក្នុងពិធីបើកសន្និសិទទស្សនៈវិស័យកម្ពុជាឆ្នាំ២០១៣ ក្រោមប្រធានបទ " ធានាអនាគតកម្ពុជា លើវិស័យស្បៀង ថាមពល និងធនធានធម្មជាតិ" នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០១៣

Alderman, H., and Ruslan Y. 2012. Productive Role of Safety Nets. Background paper for the Social Protection and Labor Strategy. Washington, DC: World Bank.

Bird, K. 2009. Building a fair future: why equity matters. London: Overseas Development Institute

CDRI. 2012. Sectoral Composition of China's Economic Growth, Poverty Reduction and Inequality: Development and Policy Implications for Cambodia. Working Paper Series No. 68. Phnom Penh, March 2012.

Goldberg, J., Hayes, W., and Huntley, J. 2004. "Understanding Health Disparities." Health Policy Institute of Ohio (November 2004), page 3.

Hang Chuon Naron. 2013. Securing Cambodia's Future: Indicators, Prospects and Policy Priorities, 2013 Cambodia Outlook Conference, 20 February 2013.

Jones, H. 2009. Equity in development: Why it is important and how to achieve it. London: Overseas Development Institute

World Bank. 2012. Resilience, Equity, and Opportunity. 2012-2022 Social Protection and Labor Strategy of the World Bank Washington, DC: World Bank.